ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍ថ្នាក់ជាតិ
# ស្តីពី
# រង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស កម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ ឆ្នាំ២០២៤ (SEA-PLM 2024) របស់កម្ពុជា



ខែធ្នូ ឆ្នាំ២០២៥

unicef for every child
SEA-PLM
Southeast Asian Ministers of Education Organization
AKCF ASEAN-KOREA COOPERATION FUND
UK International Development
ASEAN-UK SAGE Supporting the Advancement of Girls' Education

របាយការណ៍នេះត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសនៃក្រសួងអប់រំ យុវជន និងកីឡារបស់ប្រទេសកម្ពុជា ដោយមានការគាំទ្របច្ចេកទេសពីក្រុមប្រឹក្សាអូស្ត្រាលីសម្រាប់ការស្រាវជ្រាវផ្នែកអប់រំ (ACER) និងអង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ (SEAMEO) និងការគាំទ្រហិរញ្ញវត្ថុពីអង្គការ UNICEF នៅកម្ពុជា។ របាយការណ៍នេះត្រូវបានពិនិត្យ និងផ្ទៀងផ្ទាត់ដោយទីប្រឹក្សាបច្ចេកទេស លោកបណ្ឌិត Jeffery H. Marshall។ របាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយក្រោមការទទួលខុសត្រូវរបស់ក្រសួងអប់រំ យុវជន និងកីឡា ហើយមិនតំណាងឱ្យទស្សនៈជាផ្លូវការរបស់ ACER, SEAMEO ឬ UNICEF នោះទេ។

**សូមយោងឯកសារនេះដោយសរសេរថា៖**

អ.យ.ក. (២០២៥). *របាយការណ៍ថ្នាក់ជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ឆ្នាំ២០២៤ (SEA-PLM 2024) របស់កម្ពុជា*. ភ្នំពេញ: អយក

©អ.យ.ក. ២០២៥

លោកអ្នកអាចថតចម្លង ឬបោះពុម្ពឯកសារនេះសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនផ្សេងៗដូចជាឯកសារតម្កល់ បទបង្ហាញ ប្លុក គេហទំព័រ និងឯកសារបង្រៀន ប៉ុន្តែត្រូវបញ្ជាក់ថា ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកកសាងឯកសារ និងរក្សាសិទ្ធិគ្រប់យ៉ាង។

# បុព្វកថា

វិស័យអប់រំកម្ពុជាបានឈានមកដល់ចំណុចរបត់ថ្មីមួយនៃការអភិវឌ្ឍ ដែលគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃការអប់រំ ដើម្បីធានាបាននូវគុណភាព សមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិត និងបំណិនជីវិតសម្រាប់កុមារ និងយុវជន សម្រាប់រស់នៅក្នុងសង្គមប្រកបដោយភាពសុខដុមរមនា ស្របតាមស្ថានភាពសង្គម-សេដ្ឋកិច្ច តម្រូវការទីផ្សារ និងពិភពការងារដែលពោរពេញដោយការប្រកួតប្រជែង នាសតវត្សរ៍ទី២១។

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំ និងអនុវត្តកម្មវិធីជាច្រើនដែលកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ ក៏បានឆ្លើយតបនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ នៅកម្ពុជា ផែនទីបង្ហាញផ្លូវស្តីពីការអប់រំឆ្នាំ២០៣០ និងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា (២០១៦-២០៣០)។ គោលដៅចម្បងបំផុតរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺពង្រឹងប្រព័ន្ធអប់រំ ដើម្បីធានាឱ្យមានលទ្ធផលសិក្សាល្អប្រសើរ និងប្រកបដោយសមធម៌ដល់កុមារ និងយុវជនគ្រប់រូប។ ការបង្រៀន និងរៀននៅកម្រិតបឋមសិក្សា គឺជាផ្នែកដ៏សំខាន់ដែលត្រូវយកចិត្តទុកដាក់ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ និងការផ្តល់សេវាអប់រំប្រកបដោយគុណភាព។

ដើម្បីសម្រេចគោលបំណងនេះ កម្ពុជាក្នុងនាមជាសមាជិកអង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ (SEAMEO) បានចូលរួមក្នុងកម្មវិធីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM) លើកទី១ នៅឆ្នាំ២០១៩ និងលើកទី២ នៅឆ្នាំ២០២៤ ជាមួយបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងគោលបំណងវាស់វែងលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៥ និងវិភាគអំពីកត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្សនៅកម្រិតបឋមសិក្សា ព្រមទាំងកំណត់នូវសកម្មភាពនានាដើម្បីធានាថា កុមារគ្រប់រូបទទួលបានលទ្ធផលសិក្សាឱ្យកាន់តែប្រសើរឡើង។ SEA-PLM គឺជាវង្វាយតម្លៃសមត្ថភាពសិស្សលើផ្នែកអំណាន សំណេរ គណិតវិទ្យា និងភាពជាពលរដ្ឋសកល ដែលត្រូវបានចាត់ទុកជាបំណិនសតវត្សរ៍ទី២១។

របាយការណ៍ថ្នាក់ជាតិ SEA-PLM 2024 នេះ ត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមានការត្រួតពិនិត្យបច្ចេកទេសពីអ្នកជំនាញការអន្តរជាតិផងដែរ។ របាយការណ៍ SEA-PLM 2024 ថ្នាក់ជាតិនេះ បានផ្តល់ទិន្នន័យ ព័ត៌មាន និងការវិភាគលើកិច្ចការងារដែលគាំទ្រដល់យុទ្ធសាស្ត្រ និងកម្មវិធីអប់រំជាអាទិភាពនាពេលបច្ចុប្បន្ន និងអនាគត ជាពិសេសដល់ការរៀបចំ និងកែលម្អគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា។ របាយ-ការណ៍នេះ ជាមធ្យោបាយសម្រាប់ចែករំលែកមេរៀន និងបទពិសោធទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៥ ធៀបនឹងលទ្ធផលសិក្សារបស់សិស្សនៅវគ្គដំបូង និងវគ្គបន្ទាប់ទៀត ព្រមទាំងផ្តល់ឱកាសសិក្សាពីលទ្ធផលសិក្សារបស់សិស្សនៅប្រទេសដទៃក្នុងតំបន់ ដែលជាផ្នែកមួយដ៏មានតម្លៃនៃការចូលរួមរបស់កម្ពុជាក្នុងវង្វាយតម្លៃថ្នាក់តំបន់ SEA-PLM។

ក្រសួងអប់រំ យុវជន និងកីឡា នឹងប្តេជ្ញាយ៉ាងមុតមាំក្នុងការធ្វើកំណែទម្រង់វិស័យអប់រំដើម្បីឆ្លើយតបឱ្យបានពេញលេញទៅនឹងលទ្ធផលដែលបានរកឃើញនៅក្នុងរបាយការណ៍នេះ  ព្រមទាំងពិនិត្យតាមដានវឌ្ឍនភាពនៃកិច្ចអន្តរាគមន៍ដែលបានដាក់ចេញដើម្បីអាចធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផល។

ថ្ងៃពុធ ១២រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# មាតិកា

បុព្វកថា ........ i
មាតិកា........ iii
អក្សរកាត់ ........ vii
ជំពូកទី១ សេចក្ដីផ្ដើម ........ 1
1.1. ទម្រង់របាយការណ៍ថ្នាក់ជាតិ ........ 1
1.2. ប្រព័ន្ធអប់រំកម្ពុជា ........ 1
1.3. ទិដ្ឋភាពទូទៅនៃវង្វាយតម្លៃ SEA-PLM........ 2
1.3.1.គោលបំណងនៃវង្វាយតម្លៃ SEA-PLM 2
1.3.2.វិធីសាស្ត្រក្នុងវង្វាយតម្លៃ 3
ជំពូកទី២ លទ្ធផលអំណាន និងគណិតវិទ្យា........ 10
2.1. សេចក្ដីផ្ដើម ........ 10
2.2. លទ្ធផលអំណាន ........ 10
2.2.1.លទ្ធផលអំណានបង្ហាញតាមរយៈពិន្ទុ 10
2.2.2.លទ្ធផលអំណានបង្ហាញតាមរយៈកម្រិតសមត្ថភាព 11
2.3. លទ្ធផលគណិតវិទ្យា........ 11
2.3.1.លទ្ធផលគណិតវិទ្យាបង្ហាញតាមរយៈពិន្ទុ 11
2.3.2.លទ្ធផលគណិតវិទ្យាបង្ហាញតាមរយៈកម្រិតសមត្ថភាព 12
2.4. កត្តាសមធម៌........ 13
2.4.1.ភេទសិស្ស 13
2.4.2.ការគ្រប់គ្រងសាលារៀន 13
2.4.3.តំបន់សាលារៀន 14
2.4.4.ទីតាំងភូមិសាស្ត្រសាលារៀន 14
2.4.5.ស្ថានភាពសេដ្ឋកិច្ចសង្គម 15
2.5. អន្តរាគមន៍នាំឱ្យមានការកើនឡើងលទ្ធផលនៅឆ្នាំ២០២៤........ 15
2.5.1.ការពង្រីកការអប់រំកុមារតូច 15

2.5.2.ការពង្រឹងមូលដ្ឋានគ្រឹះនៃការសិក្សា 16
2.5.3.ការលើកម្ពស់សុខភាព និងអាហារូបត្ថម្ភរបស់សិស្ស 18
2.5.4.ការកែលម្អគុណភាពគ្រូបង្រៀនបឋមសិក្សា 19
2.5.5.ការរក្សាភាពធន់នៃការសិក្សាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ 20
2.5.6.ពង្រឹងអភិបាលកិច្ចសាលារៀន 20
ជំពូកទី៣ ភាពជាពលរដ្ឋសកល ........................................................ 22
3.1. សេចក្ដីផ្ដើម ........................................................ 22
3.2. ការយល់ឃើញចំពោះការអប់រំភាពជាពលរដ្ឋសកល ........................................................ 22
3.2.1.ការយល់ឃើញរបស់សិស្សអំពីប្រធានបទភាពជាពលរដ្ឋសកល ដែលបានរៀននៅសាលារៀន..22
3.2.2.ឥរិយាបថរបស់សិស្សអំពីបញ្ហាសង្គម 23
3.2.3.ការព្រួយបារម្ភរបស់សិស្សចំពោះបញ្ហាទាក់ទងនឹងភាពជាពលរដ្ឋសកល 24
3.2.4.អាកប្បកិរិយាជាពលរដ្ឋល្អរបស់សិស្ស 24
3.3. ការយល់ឃើញ និងសមត្ថភាពរបស់គ្រូបង្រៀនទាក់ទងនឹងការអប់រំភាពជាពលរដ្ឋសកល ....25
3.3.1.ឥរិយាបថរបស់គ្រូបង្រៀនចំពោះការរៀនភាពជាពលរដ្ឋសកលរបស់សិស្សនៅសាលារៀន..25
3.3.2.អាកប្បកិរិយារបស់គ្រូបង្រៀនអំពីបំណិន និងគុណតម្លៃនៃភាពជាពលរដ្ឋសកលរបស់សិស្ស26
3.3.3.ការបណ្ដុះបណ្ដាលទាក់ទងនឹងភាពជាពលរដ្ឋសកល 27
3.3.4.ទំនុកចិត្តក្នុងការបង្រៀនប្រធានបទស្ដីពីភាពជាពលរដ្ឋសកល 28
ជំពូកទី៤ ការវិភាគកត្តាដែលរួមចំណែកដល់លទ្ធផលសិក្សារបស់សិស្ស ........................................................ 29
4.1. សេចក្ដីផ្ដើម ........................................................ 29
4.2. កត្តាសិស្ស ........................................................ 29
4.2.1.អាយុសិស្ស 29
4.2.2.ការរៀនថ្នាក់មត្តេយ្យ 30
4.2.3.ការរៀនត្រួតថ្នាក់ 31
4.2.4.កម្រិតអប់រំរបស់ឪពុកម្ដាយ 33

4.2.5.ការរំពឹងទុករបស់ឪពុកម្តាយចំពោះការអប់រំរបស់កូន 33

4.2.6.ការយល់ឃើញរបស់គ្រូបង្រៀនអំពីបញ្ហាដែលប៉ះពាល់ដល់ការសិក្សារបស់សិស្ស 34

4.2.7.ការយល់ឃើញរបស់គ្រូបង្រៀនចំពោះអាកប្បកិរិយារបស់សិស្ស 35

4.2.8.ការសិក្សានៅផ្ទះក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩ 35

4.2.9.សិស្សមានតម្រូវការអប់រំពិសេស 37

4.3. កត្តាគ្រូបង្រៀន ........................................ 38

4.3.1.ភេទគ្រូបង្រៀន 38

4.3.2.អាយុគ្រូបង្រៀន 38

4.3.3.គុណវុឌ្ឍិរបស់គ្រូបង្រៀន 39

4.3.4.ការចូលរួមការបណ្តុះបណ្តាល 40

4.3.5.ការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន 41

4.3.6.ទិដ្ឋភាពសំខាន់ៗនៃសកម្មភាពអំណាន 42

4.4. កត្តាថ្នាក់រៀន ........................................ 42

4.4.1.បរិយាកាសថ្នាក់រៀន 42

4.4.2.សកម្មភាពអំណានក្នុងថ្នាក់រៀន 43

4.4.3.សកម្មភាពអានយល់ន័យក្នុងថ្នាក់រៀន 44

4.4.4.សកម្មភាពគណិតវិទ្យាក្នុងថ្នាក់រៀន 44

4.5. កត្តាសាលារៀន ........................................ 45

4.5.1.ភេទនាយកសាលា 45

4.5.2.បទពិសោធជានាយកសាលា 46

4.5.3.ទំហំសាលារៀន 46

4.5.4.ផលធៀបសិស្ស-គ្រូ 47

4.5.5.សៀវភៅសិក្សាគោល 47

4.5.6.បណ្ណាល័យ 48

4.5.7.ការត្រួតពិនិត្យវត្តមានសិស្ស 49

4.5.8.ការត្រួតពិនិត្យសាលារៀន 50
4.5.9.បញ្ហាសិស្សកើតមាននៅសាលារៀន 50
4.5.10.បញ្ហាដែលរារាំងសមត្ថភាពសាលារៀន 51
4.5.11.បញ្ហាប្រឈមរបស់សាលារៀនក្នុងអំឡុងពេលនៃជំងឺរាតត្បាតកូវីដ-១៩ 52
4.5.12.សកម្មភាពសាលារៀនឆ្លើយតបចំពោះជំងឺរាតត្បាតកូវីដ-១៩ 52
4.6. កត្តាសហគមន៍ ....... 53
4.6.1.ការចូលរួមរបស់មាតាបិតាចំពោះការសិក្សា 53
4.6.2.ការចូលរួមគាំទ្ររបស់មាតាបិតាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ 55
4.6.3.ការចូលរួមរបស់សហគមន៍ 56
ជំពូកទី៥ វិធានការលើកកម្ពស់មូលដ្ឋានគ្រឹះនៃការសិក្សា ....... 57
5.1. សេចក្តីសង្ខេបអនុសាសន៍ដកស្រង់ពីរបាយការណ៍ថ្នាក់តំបន់ ....... 57
5.2. វិធានការចម្បងៗសម្រាប់ឆ្លើយតបនឹងលទ្ធផលវង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ របស់កម្ពុជា 58
5.2.1.កែលម្អការត្រៀមខ្លួនសិក្សារបស់កុមារ តាមរយៈការអប់រំកុមារតូច 58
5.2.2.កែលម្អការសិក្សាមូលដ្ឋានគ្រឹះ តាមរយៈអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង 58
5.2.3.កែលម្អការអភិបាលកិច្ចសាលារៀននៅកម្រិតបឋមសិក្សា 58
5.2.4.កែលម្អកម្មវិធីសិក្សា និងម៉ោងបង្រៀន 60
5.2.5.ពង្រឹងសមត្ថភាពគ្រូបង្រៀន និងការអនុវត្តការបង្រៀន 60
5.2.6.កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិក្ខារសាលារៀន 61
5.2.7.លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភនៅតាមសាលារៀន 61
គន្ថនិទ្ទេស ....... 62
ឧបសម្ព័ន្ធ១ លទ្ធផលវិភាគលម្អិតរបស់ជំពូកទី២ ....... 63
ឧបសម្ព័ន្ធ២ លទ្ធផលវិភាគលម្អិតរបស់ជំពូកទី៣ ....... 66
ឧបសម្ព័ន្ធ៣ លទ្ធផលវិភាគលម្អិតរបស់ជំពូកទី៤ ....... 72

# អក្សរកាត់

| | |
|---|---|
| ACER | ក្រុមប្រឹក្សាអូស្ត្រាលីសម្រាប់ការស្រាវជ្រាវផ្នែកអប់រំ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| EAPRO | ការិយាល័យប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| EQID | នាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ |
| GC | ភាពជាពលរដ្ឋសកល |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MSD | ស្តង់ដាសាលារៀនគំរូ |
| PED | នាយកដ្ឋានបឋមសិក្សា |
| PISA | កម្មវិធីអន្តរជាតិស្តីពីរង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស |
| PISA-D | កម្មវិធីអន្តរជាតិស្តីពីរង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SEAMEO | អង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ |
| SEA-PLM | រង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ |
| UNICEF | មូលនិធិកុមារអង្គការសហប្រជាជាតិ |

# ជំពូកទី១ សេចក្ដីផ្ដើម

## 1.1. ទម្រង់របាយការណ៍ថ្នាក់ជាតិ

វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM) ត្រូវបានបង្កើតឡើងដើម្បីតាមដានវឌ្ឍនភាព និងសមិទ្ធផលរបស់សិស្សថ្នាក់ទី៥ នៅក្នុងប្រទេសនីមួយៗ និងតំបន់អាស៊ានទាំងមូល។ វដ្តទីមួយនៃ SEA-PLM បានអនុវត្តនៅឆ្នាំ២០១៩ ដែលមានប្រទេសចូលរួមចំនួន ៦ ចំណែកឯវដ្តទីពីរធ្វើឡើងនៅឆ្នាំ២០២៤ ដែលមានប្រទេសចូលរួមចំនួន ៧។

របាយការណ៍ថ្នាក់ជាតិ SEA-PLM ឆ្នាំ២០២៤ សម្រាប់កម្ពុជា ត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសនៃកម្មវិធី SEA-PLM របស់ក្រសួងអប់រំ យុវជន និងកីឡា និងមានការត្រួតពិនិត្យគុណភាពបន្ថែមដោយអ្នកជំនាញបច្ចេកទេសអន្តរជាតិ ដែលគាំទ្រពីអង្គការមូលនិធិកុមាររបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNICEF Cambodia)។ របាយការណ៍ថ្នាក់ជាតិ SEA-PLM ឆ្នាំ២០២៤ ផ្ដោតលើលទ្ធផលនៃការសិក្សារបស់សិស្សកម្ពុជាលើផ្នែកអំណាន និងគណិតវិទ្យា ព្រមទាំងសិក្សាពីកត្តាពាក់ព័ន្ធនឹងលទ្ធផលសិក្សា ដូចជាកត្តាសិស្ស កត្តាគ្រូបង្រៀន កត្តាសាលារៀន និងកត្តាមាតាបិតា/សហគមន៍។

របាយការណ៍ថ្នាក់ជាតិ SEA-PLM ត្រូវបានរៀបចំជាប្រាំជំពូក។ ជំពូកទី១ រៀបរាប់ពីទិដ្ឋភាពទូទៅនៃប្រព័ន្ធអប់រំនៅកម្ពុជា ដោយសង្ខេបអំពីប្រព័ន្ធអប់រំនៅកម្ពុជា ទិដ្ឋភាពទូទៅនៃ SEA-PLM និងវិធីសាស្ត្រវង្វាយតម្លៃ SEA-PLM។ ជំពូកទី២ បង្ហាញពីការរកឃើញសំខាន់ៗនៃលទ្ធផលសិក្សារបស់សិស្សលើផ្នែកអំណាន និងគណិតវិទ្យា ដោយផ្អែកលើពិន្ទុមាត្រដ្ឋាន (Scaled score) និងមាត្រដ្ឋានសមត្ថភាព (Proficiency scale) រួមទាំងលទ្ធផលសិក្សារបស់សិស្សនៃប្រទេសដែលបានចូលរួម។ ជំពូកទី២ ប្រៀបធៀបលទ្ធផលផ្នែកអំណាន និងគណិតវិទ្យារវាងឆ្នាំ២០១៩ និង២០២៤ ព្រមទាំងបានពិនិត្យមើលអំពីកត្តាជះឥទ្ធិពលនានា។ ជំពូកទី៣ បង្ហាញពីឥរិយាបថ និងអាកប្បកិរិយារបស់សិស្ស និងគ្រូបង្រៀនលើការយល់ដឹងអំពីភាពជាពលរដ្ឋសកល។ ជំពូកទី៤ វិភាគកត្តាផ្សេងៗដែលជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្ស។ ជំពូកទី៥ សង្ខេបអំពីការរកឃើញសំខាន់ៗ អនុសាសន៍ និងជម្រើសគោលនយោបាយព្រមទាំងវិធានការឆ្លើយតប។

## 1.2. ប្រព័ន្ធអប់រំកម្ពុជា

បន្ទាប់ពីការដួលរលំនៃរបបប្រល័យពូជសាសន៍នៅឆ្នាំ១៩៧៩ ប្រព័ន្ធអប់រំកម្ពុជាត្រូវបានរៀបចំឡើងវិញ ហើយត្រូវបានអភិវឌ្ឍបន្តិចម្ដងៗ។ ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៦ កម្ពុជាបានអនុវត្តប្រព័ន្ធអប់រំ ១០ឆ្នាំ សម្រាប់ការអប់រំចំណេះទូទៅ ដែលក្នុងនោះកម្រិតសិក្សាទី១ មាន៤ កម្រិតថ្នាក់ (ពីថ្នាក់ទី១ ដល់ថ្នាក់ទី៤), កម្រិតសិក្សាទី២ មាន ៣កម្រិតថ្នាក់ (ពីថ្នាក់ទី៥ ដល់ថ្នាក់ទី៧), និងកម្រិតសិក្សាទី៣

មាន ៣កម្រិតថ្នាក់ (ពីថ្នាក់ទី៨ ដល់ថ្នាក់ទី១០)។ ដំណាក់កាលទី២ ចាប់ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩៤ កម្ពុជាបានអនុវត្តប្រព័ន្ធអប់រំ ១១ឆ្នាំ សម្រាប់ការអប់រំចំណេះទូទៅ ដែលក្នុងនោះបឋមសិក្សា មាន ៥ កម្រិតថ្នាក់ (ពីថ្នាក់ទី១ ដល់ថ្នាក់ទី៥)។ ដំណាក់កាលទី៣ ចាប់ពីឆ្នាំ១៩៩៤ ដល់បច្ចុប្បន្ន កម្ពុជាបាន អនុវត្តប្រព័ន្ធអប់រំ ១២ឆ្នាំ សម្រាប់ការអប់រំចំណេះទូទៅ ដែលក្នុងនោះបឋមសិក្សា មាន ៦កម្រិតថ្នាក់ (ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦)។

ក្នុងចំណោមប្រទេសចំនួនប្រាំពីរដែលចូលរួម SEA-PLM ឆ្នាំ២០២៤ ប្រទេសដែលមានប្រព័ន្ធ អប់រំ ៦ឆ្នាំនៅកម្រិតបឋមសិក្សារួមមាន កម្ពុជា ម៉ាឡេស៊ី ហ្វីលីពីន និងទីម័រខាងកើត ចំណែកឯប្រទេសបី ទៀត មានត្រឹមតែ ៥ឆ្នាំសិក្សា។ អាយុចូលរៀននៅកម្រិតបឋមសិក្សាក្នុងចំណោមប្រទេសទាំងប្រាំពីរនៅ អាយុ ៦ឆ្នាំ ដូចគ្នា។

## 1.3. ទិដ្ឋភាពទូទៅនៃវង្វាយតម្លៃ SEA-PLM

វង្វាយតម្លៃ SEA-PLM គឺជាវង្វាយតម្លៃកម្រិតតំបន់ និងជាកម្មវិធីពង្រឹងសមត្ថភាពរបស់ប្រព័ន្ធអប់រំ នៃប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលស្ម័គ្រចិត្តចូលរួមជាផ្លូវការ ដើម្បីកែលម្អលទ្ធផលសិក្សារបស់ សិស្ស និងលើកកម្ពស់សមធម៌នៃការទទួលបានមូលដ្ឋានគ្រឹះនៃការអប់រំ។

វង្វាយតម្លៃ SEA-PLM ផ្តល់ជាធាតុចូលដល់ការកែទម្រង់កម្រិតគោលនយោបាយ និងកែលម្អ ប្រសិទ្ធភាពក្នុងការបង្រៀន និងការរៀន ដើម្បីលើកកម្ពស់លទ្ធផលការសិក្សារបស់សិស្ស ក៏ដូចជា សមត្ថភាពរបស់ប្រព័ន្ធអប់រំ ក្នុងការផ្តល់ឱកាសរៀនសូត្របន្ថែមទៀតដល់សិស្សនាពេលបច្ចុប្បន្ន និងអនាគត។

វង្វាយតម្លៃ SEA-PLM ត្រូវបានរៀបចំឡើង ដើម្បីវាស់វែងលទ្ធផលការសិក្សារបស់សិស្សថ្នាក់ទី៥ លើចំណេះដឹងផ្នែកអំណាន គណិតវិទ្យា និងភាពជាពលរដ្ឋសកល។

### 1.3.1. គោលបំណងនៃវង្វាយតម្លៃ SEA-PLM

គោលបំណងរួមរបស់វង្វាយតម្លៃ SEA-PLM រួមមាន៖

1. ពង្រឹងសមត្ថភាពរៀបចំ និងវិភាគទិន្នន័យវង្វាយតម្លៃលទ្ធផលសិក្សានៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
2. ពង្រឹងសមត្ថភាពប្រើប្រាស់ទិន្នន័យពីវង្វាយតម្លៃ ដើម្បីកែលម្អប្រព័ន្ធអប់រំ និងលើកកម្ពស់ លទ្ធផលសិក្សារបស់សិស្សប្រកបដោយសមធម៌នៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
3. ជំរុញការធ្វើសមាហរណកម្មវិធីសាស្ត្រវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សក្នុងតំបន់អាស៊ាន ដោយផ្តោតលើសមត្ថភាពរបស់សិស្សបឋមសិក្សាថ្នាក់ទី៥ លើអំណាន គណិតវិទ្យា និង ភាពជាពលរដ្ឋសកល។

គោលបំណងជាក់លាក់របស់របាយការណ៍នេះ រួមមាន៖

- វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៥ លើផ្នែកអំណាន និងគណិតវិទ្យាដោយផ្អែកលើកម្មវិធីសិក្សារួមនៅទូទាំងប្រទេសដែលចូលរួមវង្វាយតម្លៃ SEA-PLM
- កំណត់កត្តាសំខាន់ៗដែលរួមចំណែកដល់លទ្ធផលសិក្សារបស់សិស្ស
- ពិនិត្យមើលការយល់ឃើញរបស់សិស្សចំពោះភាពជាពលរដ្ឋសកល
- កំណត់វិធានការគោលនយោបាយឆ្លើយតបនឹងលទ្ធផលរកឃើញក្នុងវង្វាយតម្លៃ SEA-PLM ឆ្នាំ ២០២៤។

### 1.3.2. វិធីសាស្ត្រក្នុងវង្វាយតម្លៃ

#### 1.3.2.1. យន្តការប្រមូលទិន្នន័យ

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដឹកនាំ គណៈកម្មការបច្ចេកទេស និងលេខាធិការដ្ឋាននៃប្រព័ន្ធវង្វាយតម្លៃអប់រំចំណេះទូទៅ ដើម្បីទទួលបន្ទុកលើការងារវង្វាយតម្លៃលទ្ធផលសិក្សាគ្រប់ប្រភេទសិក្សា និងគ្រប់កម្រិតភូមិសិក្សា។ គណៈកម្មការនេះដឹកនាំដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងសមាជិកផ្សេងទៀតរួមមានរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក ប្រធាននាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ និងនាយកដ្ឋានជំនាញពាក់ព័ន្ធ។ ក្រុមការងារបច្ចេកទេសវង្វាយតម្លៃរួមមាន អ្នកគ្រប់គ្រងកម្មវិធីវង្វាយតម្លៃថ្នាក់ជាតិ (តំណាងដោយអគ្គនាយកអប់រំ) មន្ត្រីបច្ចេកទេសនាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ នាយកដ្ឋានជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង និងមន្ត្រីបច្ចេកទេសមកពីការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡា ទាំង២៥ រាជធានីខេត្ត។

ក្នុងដំណើរការប្រមូលទិន្នន័យ ក្រុមការងារប្រមូលទិន្នន័យ (ឬហៅថា អនុរក្សតេស្ត) និងអ្នកសម្របសម្រួលសាលារៀន ត្រូវបានបណ្តុះបណ្តាលដោយផ្អែកលើស្តង់ដាបច្ចេកទេសនៃវង្វាយតម្លៃ SEA-PLM ដែលបានកំណត់តាមដំណាក់កាលនីមួយៗយ៉ាងច្បាស់លាស់។ អនុរក្សតេស្ត ត្រូវបានជ្រើសរើសចេញពីមន្ត្រីថ្នាក់ជាតិ រួមមានមន្ត្រីមកពីនាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ និងនាយកដ្ឋានពាក់ព័ន្ធ ព្រមទាំងមន្ត្រីថ្នាក់ក្រោមជាតិ រួមមាន អធិការ/មន្ត្រីនៃការិយាល័យអធិការកិច្ច មន្ទីរអប់រំ យុវជន និងកីឡា ទាំង២៥ រាជធានីខេត្ត។ បន្ថែមលើនេះ នាយកសាលារៀនត្រូវបានជ្រើសរើសជាអ្នកសម្របសម្រួលសាលារៀន។ ការបណ្តុះបណ្តាលអំពីវិធីសាស្ត្រអនុវត្តតេស្ត ត្រូវបានអនុវត្តដោយផ្ទាល់ក្នុងរយៈពេលបីថ្ងៃ។

មន្ទីរអប់រំ យុវជន និងកីឡា ទាំង២៥ រាជធានីខេត្ត បានជួយគាំទ្រដល់ក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ និងជួយសម្របសម្រួលសាលារៀន ដើម្បីរៀបចំបញ្ជីឈ្មោះសិស្ស និងបញ្ជីឈ្មោះគ្រូ ព្រមទាំងធ្វើបច្ចុប្បន្នកម្មបញ្ជីតាមដាន និងបែងចែកសម្ភារៈធ្វើតេស្ត។

### 1.3.2.2. ការជ្រើសរើសសំណាក

ការជ្រើសរើសសំណាកនៅឆ្នាំ២០១៩ មានសាលារៀនចំនួន ១៧៧ ក្នុង ២៣ រាជធានីខេត្ត ដែលមានសិស្សថ្នាក់ទី៥ ចំនួន ៥,៣៩៦នាក់ (ស្រី ៥១.៣%), គ្រូបង្រៀនចំនួន ៣៨០នាក់ (ស្រី ៤៨.៧%), និងមាតាបិតាសិស្សចំនួន ៥,៣៧៤នាក់ (តារាង 1.1)។ ការជ្រើសរើសសំណាកនៅឆ្នាំ២០២៤ មានសាលារៀនចំនួន ១៩៥ នៅក្នុង ២៥ រាជធានីខេត្ត ដែលមានសិស្សថ្នាក់ទី៥ ចំនួន ៦,៥៧៤នាក់ (ស្រី ៤៩.៣%), គ្រូបង្រៀនចំនួន ១៩៦នាក់ (ស្រី ៥៤.១%) និងមាតាបិតាសិស្សចំនួន ៦,៥៧៤នាក់ (តារាង 1.1)។

*តារាង 1.1. ចំនួនសំណាកនៅក្នុងឆ្នាំ២០១៩ និង២០២៤*

| វដ្ត | ចំនួនសំណាក | | | | |
|---|---|---|---|---|---|
| | សាលារៀន | ថ្នាក់រៀន | គ្រូបង្រៀន | សិស្ស | មាតាបិតា |
| SEA-PLM ឆ្នាំ២០២៤ | 195 | 195 | 196 | 6,574 | 6,574 |
| SEA-PLM ឆ្នាំ២០១៩ | 177 | 177 | 380 | 5,396 | 5,374 |

ប្រទេសដែលចូលរួមទាំងអស់ បានអនុវត្តនីតិវិធីជ្រើសរើសសំណាកដូចគ្នា។ ការជ្រើសរើសសំណាកត្រូវអនុវត្តតាមពីរដំណាក់កាល (Two-stage sampling process)។ ក្នុងដំណាក់កាលទីមួយ គឺការជ្រើសរើសសាលារៀន ដោយប្រើប្រាស់វិធីសាស្ត្រចៃដន្យជាប្រព័ន្ធ (Systematic random sampling)។ ក្នុងដំណាក់កាលទីពីរ គឺការជ្រើសរើស១ថ្នាក់ ដោយចៃដន្យ ក្នុងចំណោមថ្នាក់ទី៥ សរុបនៅក្នុងសាលារៀនសំណាកនីមួយៗ ហើយសិស្សទាំងអស់នៅក្នុងថ្នាក់រៀនដែលបានជ្រើសរើសនោះត្រូវចូលរួមក្នុងការវាយតម្លៃ។

វង្វាយតម្លៃ SEA-PLM មានសៀវភៅតេស្ត ១៨ ប្រភេទ និងកម្រងសំណួរសាលារៀន សិស្ស មាតាបិតា និងគ្រូបង្រៀន។

ដោយសារឆ្នាំសិក្សា២០២៣-២០២៤ បានចាប់ផ្តើមពីខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ខែកញ្ញា ឆ្នាំ២០២៤ កម្ពុជាបានកំណត់យកកាលបរិច្ឆេទចុះប្រមូលទិន្នន័យនៅក្នុងអំឡុងខែសីហា ឆ្នាំ២០២៤ ដើម្បីធានាថាសិស្សថ្នាក់ទី៥ អាចបញ្ចប់កម្មវិធីសិក្សាបានពេញលេញ។

*តារាង 1.2. ចំនួនសាលារៀនតាមទីតាំងភូមិសាស្ត្រដែលបានចូលរួម SEA-PLM ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២៤*

| វដ្ត | ទីតាំងភូមិសាស្ត្រ | | | | | សរុប |
|---|---|---|---|---|---|---|
| | ភ្នំពេញ | ទំនាប | បឹងទន្លេសាប | ខ្ពង់រាប | មាត់សមុទ្រ | |
| SEA-PLM ឆ្នាំ២០២៤ | 17 (9%) | 56 (29%) | 54 (28%) | 49 (25%) | 19 (10%) | 195 |
| SEA-PLM ឆ្នាំ២០១៩ | 14 (8%) | 64 (36%) | 58 (33 %) | 29 (16%) | 12 (7%) | 177 |

*ចំណាំ៖ ទីតាំងភ្នំពេញត្រូវបានបំបែកចេញពីទំនាបនៅឆ្នាំ២០២៤។ ដូច្នេះលទ្ធផលឆ្នាំ២០១៩ ត្រូវបានវិភាគឡើងវិញដោយបំបែកភ្នំពេញចេញពីវាលទំនាប។*

*តារាង 1.3. ចំនួនសាលារៀនតាមតំបន់ដែលបានចូលរួម SEA-PLM ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២៤*

| វដ្ត | តំបន់ | | សរុប |
|---|---|---|---|
| | ប្រជុំជន | ជនបទ | |
| SEA-PLM ឆ្នាំ២០២៤ | 67 (34%) | 128 (66%) | 195 |
| SEA-PLM ឆ្នាំ២០១៩ | 35 (20%) | 142 ( 80%) | 177 |

### 1.3.2.3. ពិន្ទុ និងកម្រិតសមត្ថភាពនៃ SEA-PLM

រង្វាយតម្លៃ SEA-PLM បង្ហាញលទ្ធផលជាមធ្យមភាគពិន្ទុសម្រាប់មុខវិជ្ជានីមួយៗ (គណិតវិទ្យា និងអំណាន) ដែលផ្អែកលើមាត្រដ្ឋានពិន្ទុ (Scaled score) ៣០០ និងគម្លាតស្តង់ដា (Standard Deviation) ៣០។

លទ្ធផលការសិក្សារបស់សិស្សក៏ត្រូវបានបង្ហាញដោយផ្អែកលើកម្រិតសមត្ថភាព (ឬមាត្រដ្ឋាន) ដែលហៅថា Band ដើម្បីជួយសម្រួលដល់ការបកស្រាយ និងការប្រើប្រាស់លទ្ធផល។ កម្រិតសមត្ថភាពនីមួយៗ ត្រូវបានពិពណ៌នាអំពីបំណិន និងចំណេះដឹងរំពឹងទុកដែលសិស្សទទួលបាន ដើម្បីអាចឆ្លើយសំណួរទៅតាមកម្រិតសមត្ថភាពបានត្រឹមត្រូវ។ កម្រិតសមត្ថភាពមានលក្ខណៈដោយឡែកៗសម្រាប់មុខវិជ្ជានីមួយៗ ដូច្នេះ មុខវិជ្ជាទាំងអស់មិនអាចត្រូវបានយកមកប្រៀបធៀបគ្នាដោយផ្ទាល់បានទេ។

ចំពោះអំណាន រង្វាយតម្លៃ SEA-PLM បង្ហាញលទ្ធផលជាមាត្រដ្ឋានសមត្ថភាព។ កម្រិតសមត្ថភាពទាំងប្រាំ ត្រូវបានបង្កើតឡើងដោយផ្អែកលើកម្រិតលំបាកនៃសំណួរតេស្តអំណាន និងសមត្ថភាពរបស់សិស្សក្នុងការឆ្លើយសំណួរតេស្តអំណាន (តារាង 1.4)។ កម្រិតសមត្ថភាពទាំង៥ នោះរួមមាន កម្រិត២ និងក្រោមជាងនេះ, កម្រិត៣, កម្រិត៤, កម្រិត៥, កម្រិត៦ និងខ្ពស់ជាង។ កម្រិត១ មិនត្រូវបានកំណត់ទេ ហើយត្រូវបានរក្សាទុកសម្រាប់ការពង្រីកការវិភាគ SEA-PLM នាពេលអនាគត ប្រសិនបើចាំបាច់។

*តារាង 1.4. មាត្រដ្ឋាន និងសេចក្តីពិពណ៌នានៃផ្នែកអំណានរបស់វង្វាយតម្លៃ SEA-PLM*

| កម្រិតសមត្ថភាព | សេចក្តីពិពណ៌នាអំពីសមត្ថភាពសិស្ស |
|---|---|
| កម្រិត៦ និងខ្ពស់ជាង<br>ពិន្ទុ ៣១៧ និងខ្ពស់ជាង<br>(១៨.៤ ភាគរយនៃសិស្សសរុប) | **យល់អត្ថបទដោយស៊ាំនឹងរចនាសម្ព័ន្ធក្នុងអត្ថបទ និងយល់ដឹងពីព័ត៌មានស្មុគស្មាញផ្សេងៗ**<br>សិស្សយល់ពីអត្ថបទដោយស៊ាំនឹងរចនាសម្ព័ន្ធក្នុងអត្ថបទ និងយល់ដឹងពីព័ត៌មានស្មុគស្មាញផ្សេងៗនៅពេលកំណត់រកគំនិតសំខាន់ៗ និងព័ត៌មានលម្អិតក្នុងអត្ថបទ។ សិស្សស្វែងរកបណ្តុំព័ត៌មានដែលមានទំនាក់ទំនងគ្នាក្នុងរចនាសម្ព័ន្ធអត្ថបទបានយ៉ាងងាយស្រួល និងផ្សារភ្ជាប់ព័ត៌មានលម្អិតជាមួយនឹងគំនិតផ្សេងៗដើម្បីទាញរកសេចក្តីសន្និដ្ឋាន។ សិស្សប្រើប្រាស់តម្រុយ និងព័ត៌មានច្បាស់លាស់ងាយយល់ដើម្បីគាំទ្រសេចក្តីសន្និដ្ឋាននៅពេលបំពេញព័ត៌មាន។ សិស្សកំណត់បានហេតុផលជាក់លាក់ភាគច្រើនសម្រាប់ពន្យល់លើព្រឹត្តិការណ៍ណាមួយ និងប្រតិកម្មឆ្លើយតបរបស់តួអង្គក្នុងការរៀបរាប់ពីដំណើររឿងដែលព័ត៌មានទាំងនោះអាចប្រើបានចំពោះខ្លឹមសារក្នុងអត្ថបទតែប៉ុណ្ណោះ។ |
| កម្រិត៥<br>ពិន្ទុ ៣០៤ ដល់ ៣១៦<br>(២០.៥ ភាគរយនៃសិស្សសរុប) | **ភ្ជាប់ព័ត៌មានដែលមានទំនាក់ទំនងគ្នាដើម្បីយល់ពីគំនិតសំខាន់ៗ**<br>សិស្សផ្សារភ្ជាប់ទំនាក់ទំនងបណ្តុំព័ត៌មានដែលទាក់ទងគ្នាក្នុងផ្នែកផ្សេងៗនៃអត្ថបទ ដូចជាតារាង និងដ្យាក្រាមជាដើម ដើម្បីស្វែងយល់ពីគំនិតសំខាន់ៗ។ បរិបទ និងគំនិតក្នុងអត្ថបទដែលសិស្សបានជួប អាចមិនស៊ាំទាំងស្រុងដល់សិស្សទេ។ សិស្សស្គាល់ឃ្លា និងល្បះមួយចំនួនដែលមានអត្ថន័យដូចគ្នា ហើយទាញការសន្និដ្ឋានបែបសាមញ្ញនៅពេលជួបព័ត៌មានស្មុគស្មាញមួយចំនួន។ សិស្សកំណត់បានពីគោលបំណងនៃលក្ខណៈអត្ថបទខ្លីៗធ្លាប់ជួប ហើយអាចប្រើប្រាស់លក្ខណៈនៃអត្ថបទទាំងនោះដើម្បីរកព័ត៌មាន។ |
| កម្រិត៤<br>ពិន្ទុ ២៨៩ ដល់ ៣០៣<br>(២៤.៤ ភាគរយនៃសិស្សសរុប) | **យល់បានអត្ថបទសាមញ្ញៗ**<br>សិស្សអាចយល់បានអត្ថបទសាមញ្ញៗ ដែលមានគំនិត និងមានព័ត៌មានមួយចំនួនដែលសិស្សមិនធ្លាប់ជួបពីមុន។ សិស្សកំណត់បានទស្សនៈខ្លីៗមួយចំនួនដែលមានអត្ថន័យដូចគ្នា (ឧទា. ន័យដូចគ្នា) ហើយប្រើប្រាស់លក្ខណៈនៃអត្ថបទនេះដើម្បីកំណត់រកព័ត៌មានក្នុងតារាង និងក្នុងប្រភេទអត្ថបទដែលធ្លាប់ជួបដទៃផ្សេងទៀត។ សិស្សភ្ជាប់ព័ត៌មានសំខាន់ៗក្នុងប្រយោគដែលនៅជាប់គ្នា។ សិស្សទាញសេចក្តីសន្និដ្ឋានបាន នៅពេលមានតម្រុយច្បាស់លាស់ក្នុងអត្ថបទសាមញ្ញៗ។ សិស្សបកស្រាយព័ត៌មានតាមរយៈហេតុផលដែលមាននៅក្នុងអត្ថបទ និងអាចកំណត់ពីគោលបំណងនៃប្រភេទអត្ថបទងាយៗ។<br>ក្នុងការផ្គូផ្គងពាក្យទៅនឹងរូបភាព សិស្សជ្រើសរើសរវាងពាក្យដែលស្រដៀងគ្នា ប៉ុន្តែមានអត្ថន័យខុសគ្នា និងអាចកំណត់បានប្រយោគវែងដែលពណ៌នាអំពីរូបភាពនោះ។ |

| | |
|---|---|
| កម្រិត៣<br>ពិន្ទុ ២៧៤ ដល់ ២៨៨<br>(១៩.៩ ភាគរយនៃសិស្សសរុប) | **អានអត្ថបទប្រចាំថ្ងៃជាច្រើនបានយ៉ាងស្ទាត់ និងចាប់ផ្តើមយល់ន័យក្នុងអត្ថបទទាំងនោះ**<br>សិស្សអាចអានអត្ថបទប្រចាំថ្ងៃបានជាច្រើន ដូចជាអត្ថបទរឿងនិទាន និងទស្សនៈផ្ទាល់ខ្លួន ហើយចាប់ផ្តើមយល់អត្ថន័យក្នុងអត្ថបទ។ សិស្សរកព័ត៌មានលម្អិតសំខាន់ៗក្នុងអត្ថបទប្រចាំថ្ងៃ ព្រមទាំងភ្ជាប់នឹងខ្លឹមសារ/ព័ត៌មានសាមញ្ញៗដែលទាក់ទងគ្នា និងដែលអាចធ្វើឱ្យច្រឡំតិចតួច។ សិស្សធ្វើសេចក្តីសន្និដ្ឋានសាមញ្ញៗតាមរយៈព័ត៌មានក្នុងអត្ថបទ។ |
| កម្រិត២ និងក្រោម ២<br>ទាបជាងពិន្ទុ ២៧៤<br>(១៦.៩ ភាគរយនៃសិស្សសរុប) | **កំណត់បានពីទំនាក់ទំនងរវាងពាក្យ និងអត្ថន័យរបស់ពាក្យ**<br>មានសំណួរតេស្តតិចតួចប៉ុណ្ណោះនៅក្នុងវង្វាយតម្លៃ SEA-PLM ដែលទាបជាងកម្រិតសមត្ថភាពទី៣ ដូច្នេះគេមិនអាចបង្កើតសេចក្តីពណ៌នាជាទូទៅសម្រាប់សិស្សស្ថិតក្នុងសមត្ថភាពទាបជាងកម្រិតទី៣ លើផ្នែកអំណានបានទេ។ ទោះបីជាយ៉ាងនេះក៏ដោយ សំណួរតេស្តដែលមានបានបង្ហាញថា សិស្សមានសមត្ថភាពកម្រិត ២ និងអាចនៅក្រោមកម្រិត២ ជាទូទៅ អាចផ្គូផ្គងពាក្យ ១ ក្នុងចំណោមពាក្យចំនួន៤ ទៅនឹងរូបភាពវត្ថុ ទីកន្លែង និងនិមិត្តសញ្ញាដែលជាកិច្ចការសាមញ្ញត្រង់ៗ និងដដែលៗ។ នេះបង្ហាញថាសិស្សដែលស្ថិតទាបជាងកម្រិតទី៣ខាងលើ អាចយល់បានអត្ថន័យរបស់ពាក្យ។ |

ចំពោះគណិតវិទ្យា វង្វាយតម្លៃ SEA-PLM បង្ហាញលទ្ធផលមាត្រដ្ឋានសមត្ថភាព។ កម្រិតសមត្ថភាពទាំងប្រាំបី ត្រូវបានបង្កើតឡើង ដោយផ្អែកលើកម្រិតលំបាកនៃសំណួរតេស្តគណិតវិទ្យា និងសមត្ថភាពរបស់សិស្សក្នុងការឆ្លើយសំណួរតេស្តគណិតវិទ្យា (តារាង 1.5)។ កម្រិត១ ត្រូវបានរក្សាទុកសម្រាប់ការពង្រីក SEA-PLM នាពេលអនាគត។ តារាង 1.5 ពិពណ៌នាអំពីបំណិនគណិតវិទ្យា ដែលសិស្សត្រូវបានគេរំពឹងថានឹងអាចធ្វើបាននៅក្នុងកម្រិតសមត្ថភាពនីមួយៗ ពិន្ទុសម្រាប់កម្រិតនីមួយៗ និងភាគរយសិស្សនៅក្នុងកម្រិតសមត្ថភាពនីមួយៗ។

*តារាង 1.5. មាត្រដ្ឋាន និងសេចក្តីពិពណ៌នានៃមុខវិជ្ជាគណិតវិទ្យារបស់វង្វាយតម្លៃ SEA-PLM*

| កម្រិតសមត្ថភាព | សេចក្តីពិពណ៌នាអំពីសមត្ថភាពសិស្ស |
|---|---|
| កម្រិត៩ និងខ្ពស់ជាងនេះ<br>ពិន្ទុ ៣៤៧ និងខ្ពស់ជាងនេះ<br>(១.៦ ភាគរយនៃសិស្សសរុប) | មានសំណួរតេស្តតិចតួចសម្រាប់ពណ៌នាសមត្ថភាពសិស្សដែលអាចបំពេញបាននៅក្នុងកម្រិតខ្ពស់ជាងកម្រិត៨។ ទោះបីយ៉ាងណាក៏ដោយ សំណួរតេស្តដែលបង្ហាញថាសិស្សនៅកម្រិត៩ និងខ្ពស់ជាង អាចទាញហេតុផលអំពីត្រីកោណដើម្បីរកប្រវែងជ្រុងដែលមិនស្គាល់ ដោយប្រើប្រាស់ព័ត៌មានអំពីបរិមាត្រ និងសិស្សអាចដោះស្រាយចំណោទដោយប្រើប្រាស់បំណែងចែកប្រេកង់។ |
| កម្រិត៨<br>ពិន្ទុ ៣៣៥ ដល់ | **គិតពិចារណាលើប្រមាណវិធីគុណ បំប្លែងខ្នាត**<br>សិស្សអាចដោះស្រាយចំណោទដោយប្រើប្រាស់ប្រមាណវិធីបូកប្រភាគដែលមានភាគបែង |

| | |
|---|---|
| ៣៤៦<br>(៥.២ ភាគរយនៃសិស្សសរុប) | ដូចគ្នា និងដោយប្រមាណវិធីចែកចំនួនទសភាគនឹងចំនួនគត់ ១ ខ្ទង់។ សិស្សអាចបំពេញលំនាំគំរូជាចំនួនទសភាគ។ សិស្សអាចបំប្លែងសំណល់នៃម៉ោងទៅជានាទី និងសិស្សអាចគណនាពីភាពខុសគ្នារវាងប្រវែងដែលត្រូវការប្ដូរខ្នាត។ សិស្សអាចដោះស្រាយចំណោទដោយប្រើប្រាស់ក្រាបរូបភាពពីមួយទៅច្រើន។ |
| កម្រិត៧<br>ពិន្ទុ ៣២២ ដល់ ៣៣៤<br>(១២.៧ ភាគរយនៃសិស្សសរុប) | **អនុវត្តប្រភាគនិងភាគរយ និងវិភាគការតាងទិន្នន័យ**<br>សិស្សអាចគណនាភាគរយ និងប្រភាគងាយនៃមួយចំនួន។ សិស្សអាចកំណត់បានពីរង្វិលកន្លះជុំនៃរូបគំរូ។ សិស្សអាចរកតម្លៃមិនស្គាល់នៅក្នុងតារាងដោយប្រើប្រាស់តម្លៃសរុប និងគណនាតម្លៃភាគរយដែលមិនស្គាល់នៅលើក្រាបផ្ចិត។ |
| កម្រិត៦<br>ពិន្ទុ ៣០៩ ដល់ ៣២១<br>(២០.៣ ភាគរយនៃសិស្សសរុប) | **អនុវត្តប្រមាណវិធីគណិតវិទ្យាលើប្រភាគ និងបកស្រាយតារាងនិងក្រាប**<br>សិស្សអាចបំប្លែងប្រភាគមានភាគបែងតូចជាង ដប់ ទៅជាចំនួនទសភាគ។ សិស្សស្គាល់តម្លៃខ្ទង់ និងបង្គត់ចំនួនទសភាគ ដែលមានផ្នែកទសភាគហូតដល់ ៥ ខ្ទង់។ សិស្សអាចដោះស្រាយចំណោទទាក់ទងនឹងឧបករណ៍រង្វាស់រង្វាល់ ដែលត្រូវការបំប្លែងខ្នាតប្រវែង និងខ្នាតចំណុះ។ សិស្សអាចគណនាទម្ងន់នៃវត្ថុដោយប្រើប្រាស់ជញ្ជីង។<br>សិស្សអាចបូក ៣០ នាទី បន្ថែមលើពេលវេលាដែលគេឱ្យ។ សិស្សអាចចង្អុលបង្ហាញវត្ថុដែលមានវិមាត្រ ៣ ចេញពីរូបតំណាងជារូបធរណីមាត្រវិមាត្រ ២ និងបកស្រាយផែនទីងាយៗ ដោយប្រើប្រាស់ភាសាបញ្ជាក់ទិសដៅ។ សិស្សបកស្រាយតារាងប្រេកង់ និងក្រាបខ្សែដែលបង្ហាញពីកំណើនតាមពេល។ |
| កម្រិត៥<br>ពិន្ទុ ២៩៦ ដល់ ៣០៨<br>(២២.៣ ភាគរយនៃសិស្សសរុប) | **ដោះស្រាយចំណោទដោយប្រើប្រាស់ប្រមាណវិធីនព្វន្តយ៉ាងស្ទាត់ជំនាញ**<br>សិស្សអាចធ្វើប្រមាណវិធីបូកចំនួនគត់ដែលមានលេខ ៤ ខ្ទង់ និងប្រមាណវិធីដកចំនួនគត់ដែលមានលេខ ២ ខ្ទង់នៅក្នុងបរិបទប្រចាំថ្ងៃ ហើយសិស្សអាចកំណត់ចំនួនគត់ដែលមានលេខ ៥ ខ្ទង់ បានតាមរយៈពាក្យអានចំនួនដែលគេឱ្យ។ សិស្សអាចរាប់ចំនួនងាយៗបន្តក្នុងលំនាំគំរូលេខ។ សិស្សអាចបំពេញលំនាំគំរូតាមរាងធរណីមាត្រ។ សិស្សអាចបង្កើតវិធានដោះស្រាយចំណោទដោយប្រើប្រាស់ប្រមាណវិធីគុណនិងចែក។ សិស្សយល់ពីលំនាំនៃការកំណត់តម្លៃពាក់កណ្ដាលនៃបរិមាណមួយ។ សិស្សអាចប៉ាន់ស្មានចំណុះចេញពីស៊ីឡាំងក្រិត និងអាចប្រៀបធៀបមុំធៀបនឹងមុំកែង។ សិស្សអាចប៉ាន់ស្មានទម្ងន់នៃវត្ថុ។ សិស្សអាចអានចំនួននៅក្នុងតារាង និងផលបូកនៃចំនួនទាំងនោះដែលនៅក្នុងតារាង។ សិស្សយល់ពីសំណង់នៃក្រាបសសរដែលបង្ហាញបរិមាណតាមពេល។ |

| | |
|---|---|
| កម្រិត៤<br>ពិន្ទុ ២៨៣ ដល់ ២៩៥<br>(១៨.៤ ភាគរយនៃសិស្សសរុប) | **អនុវត្តលក្ខណៈចំនួន និងខ្នាតរង្វាស់រង្វាល់**<br>សិស្សអាចរកតម្លៃពាក់កណ្តាលនៃចំនួនគត់គូដែលមានលេខ១ ខ្ទង់ និងយល់ច្បាស់ពីតម្លៃខ្ទង់នៃចំនួនទសភាគដែលមានផ្នែកទសភាគ ៥ ខ្ទង់ ។ សិស្សអាចដោះស្រាយចំណោទទាក់ទងនឹងចំណុះដែលមិនត្រូវការប្តូរខ្នាត។ សិស្សប្រើប្រាស់ចំណេះដឹងរបស់ពួកគេអំពីចំនួននាទីក្នុងមួយម៉ោង។ សិស្សអាចអានតម្លៃលេខលើក្រាបសសរ។ |
| កម្រិត៣<br>ពិន្ទុ ២៦៩ ដល់ ២៨២<br>(១១.៧ ភាគរយនៃសិស្សសរុប) | **យល់ច្បាស់ពីតម្លៃខ្ទង់ និងទំហំនៃរង្វាស់រង្វាល់**<br>សិស្សអាចរៀបលំដាប់ចំនួនគត់ដែលមានលេខ ២ ខ្ទង់។ សិស្សអាចអានតម្លៃប្រវែង និងរង្វាស់ទម្ងន់លើឧបករណ៍រង្វាស់រង្វាល់ ដែលត្រូវការប៉ាន់ស្មានមួយចំនួន។ សិស្សអាចស្គាល់រូបធរណីមាត្រងាយៗ និងប្រៀបធៀបមុំ។ សិស្សអាចបកស្រាយក្រាបសសរងាយៗ។ |
| កម្រិត២ និងក្រោម ២<br>ទាបជាងពិន្ទុ ២៦៩<br>(៧.៩ ភាគរយនៃសិស្សសរុប) | មានសំណួរតេស្តតិចតួចសម្រាប់ពណ៌នាសមត្ថភាពសិស្សអាចដែលបំពេញបាននៅកម្រិតទាបជាងកម្រិត៣។ សិស្សមួយចំនួនគួរតែមានសមត្ថភាពធ្វើប្រមាណវិធីបូកចំនួនគត់ដែលមានលេខមួយខ្ទង់ និងចំនួនគត់ដែលមានលេខមួយខ្ទង់។ សិស្សផ្សេងទៀតអាចមានសមត្ថភាពរាប់សំណុំនៃវត្ថុ ឬអាចស្គាល់ចំនួន។ |

# ជំពូកទី២ លទ្ធផលអំណាន និងគណិតវិទ្យា

## 2.1. សេចក្តីផ្តើម

វង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ បានអនុវត្តនៅចុងបញ្ចប់នៃឆ្នាំសិក្សា២០២៣-២០២៤ នៅក្នុងប្រទេសចំនួនប្រាំពីរនៅក្នុងតំបន់ រួមមាន កម្ពុជា ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន វៀតណាម និងទីម័រខាងកើត។ ប៉ុន្តែលទ្ធផលរបស់ទីម័រខាងកើតមិនទាន់អាចបង្ហាញក្នុងរបាយការណ៍ថ្នាក់តំបន់នៅឡើយទេ ដោយសារប្រទេសទីម័រខាងកើតស្នើសុំប្រើប្រាស់សម្រាប់កម្រិតផ្ទៃក្នុងប្រទេស។

ជំពូកនេះសង្ខេបអំពីលទ្ធផលរបស់សិស្សថ្នាក់ទី៥ នៅកម្ពុជា ដែលបានចូលរួមក្នុងវង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ លើផ្នែកអំណាន និងគណិតវិទ្យា។ ជំពូកនេះក៏មានបញ្ចូលទាំងសេចក្តីសង្ខេបលទ្ធផលនៅវដ្តឆ្នាំ២០២៤ និងការប្រៀបធៀបលទ្ធផលការសិក្សារបស់សិស្សរវាងឆ្នាំ២០១៩ និង២០២៤ ដោយប្រើពិន្ទុបំប្លែង (Equated score)។ ពិន្ទុរបស់សិស្ស ត្រូវបានសង្ខេបដោយផ្អែកលើមាត្រដ្ឋានពិន្ទុនៅក្នុងមុខវិជ្ជានីមួយៗ (បើប្រៀបធៀបទៅនឹងពិន្ទុដើមគ្រាឆ្នាំ២០១៩ ដែលមានមធ្យមពិន្ទុ ៣០០) និងមាត្រដ្ឋានសមត្ថភាព (ឧ. កម្រិតសមត្ថភាព) ដែលពិពណ៌នាអំពីអ្វីដែលសិស្សនៅក្នុងប្រទេសចូលរួមយល់ដឹង និងអាចធ្វើបាន។

## 2.2. លទ្ធផលអំណាន

### 2.2.1. លទ្ធផលអំណានបង្ហាញតាមរយៈពិន្ទុ

ពិន្ទុមធ្យមអំណានរបស់អាស៊ាននៅក្នុងវង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ គឺ ៣០០ ពិន្ទុ ដែលដូចគ្នានឹងឆ្នាំ ២០១៩។ អំណានរបស់កម្ពុជាស្ថិតនៅទីបីក្នុងចំណោមប្រទេសទាំងប្រាំមួយ ដោយមានការកើនឡើងប្រាំមួយពិន្ទុ (ពី ២៩០ ដល់ ២៩៦) ចំណែកឯ វៀតណាម និងម៉ាឡេស៊ីមានការថយចុះ។

*រូប 2.1. លទ្ធផលអំណានក្នុងវង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ តាមប្រទេសចូលរួមនីមួយៗ*




**លទ្ធផលរបស់មីយ៉ាន់ម៉ា មិនតំណាងឱ្យសិស្សទូទាំងប្រទេស ដោយសារស្ថានភាពផ្ទៃក្នុងប្រទេស។*

### 2.2.2. លទ្ធផលអំណានបង្ហាញតាមរយៈកម្រិតសមត្ថភាព

ចំពោះអំណាន ភាគរយសិស្សកម្ពុជាដែលមានសមត្ថភាពខ្ពស់ (ចាប់ពីកម្រិត៥ និងខ្ពស់ជាងនេះ) បានកើនឡើងពី ២៧% ក្នុងឆ្នាំ២០១៩ ដល់ ៣៩% ក្នុងឆ្នាំ២០២៤។ ក្នុងចំណោមសិស្សទាំងនេះ ភាគរយសិស្សដែលសម្រេចបានលទ្ធផលខ្ពស់បានកើនឡើងពី ១១% ដល់ ១៨% (សូមមើលរូប 2.2)។ សិស្សទាំងនេះ ទោះបីជានៅថ្នាក់ទី៥ ក៏ដោយ ក៏អាចមានលទ្ធផលល្អដូចសិស្សដែលបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សានៅទូទាំងប្រទេសចូលរួមដទៃទៀតដែរ។ ជាពិសេស ភាគរយសិស្សដែលមិនអាចអានអត្ថបទសាមញ្ញបានយ៉ាងស្ទាត់ជំនាញ (កម្រិត៣ និងទាបជាងនេះ) បានថយចុះពី ៤៧% ក្នុងឆ្នាំ២០១៩ មកដល់ ៣៧% ក្នុងឆ្នាំ២០២៤។

*រូប 2.2.ភាគរយសិស្សកម្ពុជាថ្នាក់ទី៥ នៅតាមកម្រិតសមត្ថភាពនីមួយៗរបស់អំណាននៅក្នុងឆ្នាំ២០១៩ និង ២០២៤*




## 2.3. លទ្ធផលគណិតវិទ្យា

### 2.3.1. លទ្ធផលគណិតវិទ្យាបង្ហាញតាមរយៈពិន្ទុ

ពិន្ទុមធ្យមគណិតវិទ្យារបស់អាស៊ានក្នុងរង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ គឺ ៣០០ ពិន្ទុ ដែលដូចគ្នានឹងឆ្នាំ២០១៩។ ពិន្ទុមធ្យមរបស់សិស្សថ្នាក់ទី៥ កម្ពុជាបានកើនឡើងពី ២៨៩ ពិន្ទុក្នុងឆ្នាំ២០១៩ ដល់ ៣០១ ពិន្ទុ ក្នុងឆ្នាំ២០២៤។ សេចក្តីសង្ខេបក្នុងរូប 2.3 បង្ហាញតែមធ្យមភាគឆ្នាំ២០២៤ ប៉ុណ្ណោះ។ មធ្យមភាគគណិតវិទ្យារបស់កម្ពុជាគឺខ្ពស់ជាងប្រទេសពីរផ្សេងទៀត (ឡាវ និងហ្វីលីពីន) ប៉ុន្តែទាបជាងមធ្យមភាគរបស់ប្រទេសបីផ្សេងទៀត។

*រូប 2.3. លទ្ធផលគណិតវិទ្យាក្នុងរង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ តាមប្រទេសចូលរួមនីមួយៗ*




**លទ្ធផលរបស់មីយ៉ាន់ម៉ា មិនតំណាងឱ្យសិស្សទូទាំងប្រទេស ដោយសារស្ថានភាពផ្ទៃក្នុងប្រទេស។*

## 2.3.2. លទ្ធផលគណិតវិទ្យាបង្ហាញតាមរយៈកម្រិតសមត្ថភាព

ចំពោះគណិតវិទ្យា ភាគរយសិស្សកម្ពុជាដែលមានសមត្ថភាពខ្ពស់ (ចាប់ពីកម្រិត៥ និងខ្ពស់ជាងនេះ) បានកើនឡើងពី ៣៩% ក្នុងឆ្នាំ២០១៩ ដល់ ៦២% ក្នុងឆ្នាំ២០២៤។ ក្នុងចំណោមសិស្សទាំងនេះ ភាគរយសិស្សដែលសម្រេចបានលទ្ធផលខ្ពស់ (កម្រិត៦ ឡើងទៅ) បានកើនឡើងពី ១៩% ដល់ ៤០% (សូមមើលរូប 2.4)។ សិស្សទាំងនេះអាចអនុវត្តបានល្អប្រសើរដូចសិស្សដែលបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សានៅទូទាំងប្រទេសដែលចូលរួមដទៃទៀត។ គួរឱ្យចាប់អារម្មណ៍ថា ភាគរយសិស្សដែលមានសមត្ថភាពទាប ដែលអាចយល់បានត្រឹមចំនួនទសភាគ និងអានរង្វាស់ជាប្រវែង និងទម្ងន់ (កម្រិត៣ និងទាបជាងនេះ) បានថយចុះពី ៣៦% ក្នុងឆ្នាំ២០១៩ មកដល់ ២០% ក្នុងឆ្នាំ២០២៤។

*រូប 2.4. ភាគរយសិស្សកម្ពុជាថ្នាក់ទី៥ នៅតាមកម្រិតសមត្ថភាពនីមួយៗរបស់គណិតវិទ្យានៅក្នុងឆ្នាំ២០១៩ និង២០២៤*



## 2.4. ភត្តាសមធម៌

### 2.4.1. ភេទសិស្ស

រូប 2.5 សង្ខេបលទ្ធផលរបស់សិស្សថ្នាក់ទី៥ ក្នុងឆ្នាំ២០១៩ និង២០២៤ តាមភេទសិស្ស។ សិស្សស្រីមានលទ្ធផលល្អជាងសិស្សប្រុសទាំងពីរមុខវិជ្ជា និងទាំងពីរវដ្ត។ ចំពោះអំណាន សិស្សស្រីមានលទ្ធផលល្អជាងសិស្សប្រុស (៩ពិន្ទុ)។

*រូប 2.5. លទ្ធផលអំណាន និងគណិតវិទ្យាតាមភេទសិស្សនៅឆ្នាំ២០១៩ និង២០២៤*




### 2.4.2. ការគ្រប់គ្រងសាលារៀន

សិស្សមកពីសាលារៀនឯកជនទទួលបានពិន្ទុខ្ពស់ជាងសិស្សមកពីសាលារៀនសាធារណៈទាំងពីរមុខវិជ្ជា។ គម្លាតលទ្ធផលរវាងសាលារៀនសាធារណៈ និងសាលារៀនឯកជន បានកាត់បន្ថយនៅឆ្នាំ២០២៤ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩។ រូប 2.6 បង្ហាញពីលទ្ធផលរបស់សិស្សថ្នាក់ទី៥ ក្នុងឆ្នាំ២០២៤ តាមប្រភេទការគ្រប់គ្រងសាលារៀន។

*រូប 2.6. លទ្ធផលអំណាន និងគណិតវិទ្យាតាមប្រភេទការគ្រប់គ្រងសាលារៀននៅឆ្នាំ២០១៩ និង២០២៤*



### 2.4.3. តំបន់សាលារៀន

នៅក្នុងប្រទេសកម្ពុជា តាមរយៈ EMIS ទីតាំងសាលារៀនត្រូវបានបែងចែកជាពីរតំបន់ រួមមាន ជនបទ និងប្រជុំជន។ គម្លាតលទ្ធផលរវាងសាលារៀននៅតំបន់ប្រជុំជន និងជនបទត្រូវបានកាត់បន្ថយនៅក្នុងឆ្នាំ២០២៤ បើធៀបនឹងឆ្នាំ២០១៩។ រូប 2.7 បង្ហាញពីលទ្ធផលរបស់សិស្សថ្នាក់ទី៥ ក្នុងឆ្នាំ២០២៤ តាមទីតាំងសាលារៀន។

*រូប 2.7. លទ្ធផលអំណាន និងគណិតវិទ្យាតាមទីតាំងសាលារៀននៅឆ្នាំ២០១៩ និង២០២៤*




### 2.4.4. ទីតាំងភូមិសាស្រ្តសាលារៀន

សាលារៀនសំណាកត្រូវបានចាត់ថ្នាក់តាមទីតាំងភូមិសាស្រ្ត។ រូប 2.8 បង្ហាញថា លទ្ធផលរបស់សិស្សថ្នាក់ទី៥ ក្នុងឆ្នាំ២០២៤ បានកើនឡើង បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ ទាំងពីរមុខវិជ្ជា និងគ្រប់ទីតាំងតំបន់ភូមិសាស្រ្ត។

*រូប 2.8 លទ្ធផលអំណាន និងគណិតវិទ្យាតាមទីតាំងភូមិសាស្រ្តសាលារៀននៅឆ្នាំ២០១៩ និង២០២៤*



### 2.4.5. ស្ថានភាពសេដ្ឋកិច្ចសង្គម

នៅក្នុងវង្វាយតម្លៃ SEA-PLM សូចនាករស្ថានភាពសេដ្ឋកិច្ចសង្គម (SES) ត្រូវបានបង្កើតឡើង ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ចសង្គមរបស់គ្រួសារ ហើយសូចនាករនេះត្រូវបានបែងចែកជាបួនកម្រិត រួមមាន កាទីលខាងក្រោម (ជីវភាពក្រីក្រ), កាទីលទីពីរ, កាទីលទីបី, និង កាទីលខាងលើ (ជីវភាពធូរធារ)។ លទ្ធផលរបស់សិស្សមកពីគ្រួសារក្រីក្រ ក្នុងមុខវិជ្ជាទាំងពីរមានភាពប្រសើរវាងឆ្នាំ២០១៩ និង ២០២៤ ប៉ុន្តែគម្លាតរវាងលទ្ធផលរវាងសិស្សមកពីគ្រួសារក្រីក្រ និងគ្រួសារធូរធារនៅតែមានទំហំធំ។ រូប 2.9 បង្ហាញពីលទ្ធផលរបស់សិស្សថ្នាក់ទី៥ ក្នុងឆ្នាំ២០១៩ និង២០២៤ តាមកម្រិតជីវភាព។

*រូប 2.9. លទ្ធផលអំណាន និងគណិតវិទ្យាតាមកម្រិតស្ថានភាពសេដ្ឋកិច្ចសង្គមនៅឆ្នាំ២០១៩ និង២០២៤*




## 2.5. អន្តរាគមន៍នាំឱ្យមានការកើនឡើងលទ្ធផលនៅឆ្នាំ២០២៤

### 2.5.1. ការពង្រីកការអប់រំកុមារតូច

- បានពង្រីកសេវាអប់រំកុមារតូច ដោយសាងសង់សាលាមត្តេយ្យនៅក្នុងសហគមន៍ដែលខ្វះខាត ការផ្តល់សម្ភារៈ និងធនធានមត្តេយ្យសិក្សាដែលមានគុណភាពខ្ពស់ និងពង្រីកការបណ្តុះបណ្តាលគ្រូមត្តេយ្យ។
- អត្រាចុះឈ្មោះចូលរៀនរបស់កុមារអាយុ៥ឆ្នាំ គ្រប់រូបភាពមានវឌ្ឍនភាពល្អប្រសើរឡើង នៅក្នុងអំឡុងពេល១០ឆ្នាំ ចុងក្រោយនេះ។ នៅឆ្នាំសិក្សា២០១៤-២០១៥ កុមារអាយុ ៥ឆ្នាំ មាន ៦១,៤% ស្រី ៥០,៣% កើនដល់ ៧១,៤% ស្រី ៧១,៩% នៅឆ្នាំសិក្សា២០២៤-២០២៥។ ផ្អែកតាមវឌ្ឍនភាពនេះបង្ហាញថា អត្រាកុមារអាយុ ៥ឆ្នាំបានចូលរៀនគ្រប់រូបភាពមានកំណើន ០,៩% ស្រី ១,៩% ក្នុង ១ឆ្នាំសិក្សា។

- កុមារអាយុ៦ឆ្នាំឆ្លងកាត់សេវាអប់រំកុមារតូចគ្រប់រូបភាពបានចូលរៀនថ្នាក់ទី១ នៃសាលាបឋមសិក្សា ៥៧,៩០% ស្រី ៦២,០% នៅឆ្នាំសិក្សា២០១៤-២០១៥ កើនដល់ ៧៩,៦៩% ស្រី ៨១,២៤% នៅឆ្នាំសិក្សា២០២៤-២០២៥ក្នុងនោះ មត្តេយ្យសិក្សារដ្ឋកើនពី ៣៧,៣០% ស្រី ៣៦,៩៧% ដល់៥៨,៧៣% ស្រី ៥៩,៨៧% មត្តេយ្យសិក្សាឯកជនកើនពី ៤,០% ស្រី ៣,៧៦% ដល់ ១០,០៧% ស្រី ១០,១៤% មត្តេយ្យសិក្សាសហគមន៍កើនពី ៩,៤០% ស្រី ៩,៧១% ដល់ ១០,៧៩% ស្រី ១១,២៣%។
- ប្រៀបធៀបឆ្នាំ ២០១៩ និង ២០២៤ ភាគរយសិស្សដែលបានចូលរៀនថ្នាក់មត្តេយ្យសិក្សាបាន ១ ឆ្នាំ ឬច្រើនជាងនេះ បានកើនឡើងពី ៥៨% ដល់ ៨០% ដែលបង្ហាញថាមានសិស្សកាន់តែច្រើន បានឆ្លងកាត់មត្តេយ្យសិក្សា មុនចូលរៀននៅបឋមសិក្សា។

## 2.5.2. ការពង្រឹងមូលដ្ឋានគ្រឹះនៃការសិក្សា

- បានអនុវត្តកញ្ចប់អំណាន និងគណិតវិទ្យាថ្នាក់ដំបូង ដោយពង្រីកការអនុវត្តកញ្ចប់អំណាន សម្រាប់ថ្នាក់ទី១ ទី២ និងទី៣ ទូទាំងប្រទេស និងពង្រីកការអនុវត្តកញ្ចប់គណិតវិទ្យាបន្តិចម្តងៗ។ ក្នុងពេលជាមួយគ្នានេះ កញ្ចប់អំណាន និងគណិតវិទ្យាថ្នាក់ដំបូងត្រូវបានដាក់បញ្ចូលទៅក្នុង កម្មវិធីបណ្តុះបណ្តាលគ្រូ ទាំងក្នុងប្រព័ន្ធបណ្តុះបណ្តាល ១២+២ និង ១២+4 ដើម្បីធានាបាននូវ និរន្តរភាព រួមទាំងការអនុវត្តយន្តការប្រឹក្សាគរុកោសល្យ។

### 2.5.2.1 បំណិនអំណាន

#### 1. ចលនាការលើកកម្ពស់អក្ខរកម្ម

- នៅឆ្នាំ ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តឡើងវិញការរៀនតែងសេចក្តី និង ការសរសេរតាមអាននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។
- នៅឆ្នាំ ២០១៦ ក្រសួងបានសាកល្បងអនុវត្តកញ្ចប់អំណានថ្នាក់ដំបូងថ្នាក់ទី១ ជាមួយដៃគូ អភិវឌ្ឍនៅតាមសាលាបឋមសិក្សាមួយចំនួន។
- ចាប់ពីឆ្នាំ ២០១៨ ក្រសួងបានចាប់អនុវត្តជាផ្លូវការទូទាំងប្រទេស នូវកញ្ចប់សម្ភារអំណានថ្នាក់ ដំបូង រួមមាន សៀវភៅណែនាំសម្រាប់គ្រូ សៀវភៅជំនួយសិស្ស បណ្ណអក្សរ-រូបភាព សៀវភៅហ្វឹកហាត់សរសេរ និងសៀវភៅរឿង ៦០ ចំណងជើង។

#### 2. ពិនិត្យឡើងវិញវិធីសាស្ត្របង្រៀនអំណាន

- ក្រសួងបានអនុវត្តវិធីសាស្ត្របង្រៀនតាមបែបស្គាល់សូរ ឬ វិធីសំយោគ (Methode synthetique) គឺជាការបង្រៀនផ្តោតលើការស្គាល់សូរនៃព្យញ្ជនៈ និង ស្រៈ វិធីសាស្ត្រក្នុងការផ្សំប្រកប បំបែកសូរ និងបង្រៀនព្យាង្គតម្រួត។ ការបង្រៀនមេរៀនព្យាង្គតម្រួតដល់សិស្សកម្រិតថ្នាក់ដំបូង មានសារៈ សំខាន់ជួយឱ្យសិស្សចេះផ្សំប្រកបដោយប្រើវិធីញែកព្យាង្គដើម្បីអានពាក្យបានត្រឹមត្រូវ។

- ក្រសួងបានអនុវត្តវិធីសាស្ត្របង្រៀនតាមបែបសរុប (Whole-word approach) គឺជាការបង្រៀនដោយផ្តោតលើឃ្លាដែលមានអត្ថន័យមួយ ឬពាក្យដែលមានន័យមួយ ដែលផ្ទុយពីវិធីសាស្ត្រសំយោគ ដែលផ្តើមពីការបង្រៀនតួអក្សរ «អក្ខរក្រម» ដើម្បីឈានទៅបង្កើតព្យាង្គ (ការផ្សំផ្គុំព្យញ្ជនៈ ជាមួយស្រៈ) បង្កើតពាក្យរួចបង្កើតល្បះ។
- ការលើកកម្ពស់អំណានត្រូវប្រើប្រាស់វិធីសាស្ត្រទាំងពីរបែបខាងលើរួមគ្នា។

### 3. ពិនិត្យឡើងវិញគោលការណ៍បង្រៀន (ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ)

- ក្រសួងបានជំរុញឱ្យគ្រូបង្រៀនអនុវត្តគោលការណ៍ "ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ" ដើម្បីលើកទឹកចិត្តការចូលរួមរបស់សិស្សក្នុងសកម្មភាពរៀនប្រកបដោយទំនុកចិត្ត និងមោទនភាពដោយផ្តល់ការទទួលខុសត្រូវដល់សិស្សបន្តិចម្តងៗ តាមរយៈការអនុវត្តជាជំហានៗដោយមានការជួយគាំទ្រដល់ដំណើរការនៃការរៀន។

### 4. ជំរុញសកម្មភាពអំណានក្នុងបណ្ណាល័យ

- សកម្មភាពអំណានក្នុងបណ្ណាល័យ រួមមានអំណានឮ អំណានចូលរួម អំណានដៃគូ និងអំណានបុគ្គល។

## 2.5.2.2 បំណិនគណិតវិទ្យា

### 1. ការរៀបចំកញ្ចប់សម្ភារគណិតវិទ្យាថ្នាក់ដំបូង

- ការរៀបចំកញ្ចប់សម្ភារគណិតវិទ្យាថ្នាក់ដំបូង មានគោលបំណងផ្តល់ការគាំទ្រលើវិធីសាស្ត្របង្រៀនគណិតវិទ្យាថ្នាក់ទី១ ថ្នាក់ទី២ និងថ្នាក់ទី៣ ឱ្យឆ្លើយតបទៅនឹងសមត្ថភាព និងលទ្ធផលនៃការសិក្សារបស់សិស្ស។

### 2. ជំរុញការផលិតសម្ភារឧបទេសសម្រាប់ការបង្រៀនគណិតវិទ្យា

- សម្ភារឧបទេស ជួយជំរុញសិស្សឱ្យមានសកម្មភាពរស់រវើកក្នុងពេលរៀនគណិតវិទ្យា ដោយជួយឱ្យពួកគេផ្សារភ្ជាប់ពីរូបីទៅអរូបី ព្រមទាំងអាចផ្តល់នូវបទពិសោធសម្បូរបែបក្នុងការរៀន និងបង្រៀនផងដែរ។
- សម្ភារឧបទេស អាចជួយឱ្យសិស្សបង្កើតរូបភាពក្នុងគំនិត និងយល់ច្បាស់កាន់តែស៊ីជម្រៅ ព្រមទាំងចៀសវាងបាននូវគំនិតភាន់ច្រឡំ។ សម្ភារឧបទេស ក៏ជាគន្លឹះនិងជាផ្នែកមួយដែលអាចជួយឱ្យពួកគេ យល់ពីបញ្ញត្តិ ឬដោះស្រាយលំហាត់នោះបានផងដែរ។ ម្យ៉ាងទៀត វាជួយឱ្យសិស្សរៀនសង្កេត វិភាគ និងធ្វើការសន្និដ្ឋាន ដើម្បីចងក្រងក្បួនច្បាប់ រូបមន្ត ជាពិសេស វាផ្សារភ្ជាប់នឹងជីវភាពរស់នៅជាក់ស្តែង ធ្វើឱ្យសិស្សចងចាំខ្លឹមសារមេរៀនបានយូរ សិស្សចាប់អារម្មណ៍ សប្បាយរីករាយក្នុងម៉ោងរៀន ហើយវាឆ្លើយតបនឹងការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល។

### 3. ពិនិត្យឡើងវិញវិធីសាស្ត្របង្រៀនគណិតវិទ្យាថ្នាក់ដំបូង

- វិធីសាស្ត្របង្រៀន គឺជាបច្ចេកទេសរួម ជាបណ្តុំវិធី ជារបៀប ជាបែបបទ ជាការណែនាំដែលចងក្រងជាលំនាំ ជាប្រព័ន្ធ ឬជាផែនការសកម្មភាពនៃការអប់រំ ដើម្បីឱ្យការរៀននិងបង្រៀនមានសណ្តាប់ធ្នាប់បែបវិទ្យាសាស្ត្រមានលក្ខណៈជាជំហានៗ ឈរលើអន្តរកម្មរវាងសកម្មភាពគ្រូ និងសិស្សទៅលើខ្លឹមសារមេរៀនដើម្បីសម្រេចវត្ថុបំណងមេរៀនហើយឆ្លើយតបតាមគោលវិធីដែលបានកំណត់។
- ការបង្រៀនគណិតវិទ្យាត្រូវប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល ដោយផ្តោតលើវិធីនៃការផ្តល់បញ្ញត្តិតាមរយៈសកម្មភាព៖ គ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើ។

### 4. វិធីសាស្ត្របង្រៀនចំណោទ

- សកម្មភាពនេះ គ្រូអាចបង្រៀនសិស្សពីវិធីដោះស្រាយចំណោទ ឱ្យសិស្សដោះស្រាយចំណោទ និងលំហាត់គណិតវិទ្យាទៅតាមខ្លឹមសារមេរៀន។
- វិធីដោះស្រាយចំណោទតាមវិធី POLYA មាន៤ជំហាន៖
  - ការយល់ដឹងពីចំណោទ៖ អានប្រធានចំណោទពីរ ឬបីដង តើគេប្រាប់អ្វីខ្លះ? គេសួររកអ្វី?
  - ការបង្កើតផែនការ៖ រកមធ្យោបាយដែលត្រូវដោះស្រាយ (ប្រើរូបមន្ត ប្រមាណវិធី ឬរូបតំណាង)
  - ការអនុវត្តផែនការ៖ ដោះស្រាយដោយផ្អែកលើផែនការដែលបានកំណត់
  - ការពិនិត្យមើលឡើងវិញ៖ ដើម្បីបំពេញលក្ខខណ្ឌនៃចំណោទ។

## 2.5.3. ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភរបស់សិស្ស

### 1. ការលើកកម្ពស់សុខភាពសិក្សា

- ក្នុងបរិបទនៃគន្លងប្រក្រតីភាពថ្មីក្នុងវិស័យអប់រំ សាលារៀនត្រូវធានាបាននិរន្តរភាពនៃដំណើរការ និងធានាសុវត្ថិភាពសុខភាព រួមទាំងសុខភាពផ្លូវចិត្តសម្រាប់បុគ្គលិកអប់រំ និងសិស្សានុសិស្ស។ ដូចនេះ សាលារៀនត្រូវ៖ ១) បង្កើតគណៈកម្មការសុខភាពសិក្សានៅតាមសាលារៀន ២) កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាព ដូចជា រៀបចំបន្ទប់សុខភាពស្តង់ដា បរិស្ថានសាលារៀនបៃតង សាលារៀនស្អាតគ្មានសំរាម ៣) លើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ ផ្តោតលើទឹកទទួលទាន កន្លែងលាងដៃ បង្គន់អនាម័យ ការពាក់ម៉ាស់ និងការរក្សាគម្លាត ៤) លើកកម្ពស់អាហារូបត្ថម្ភ ដោយផ្តោតលើសុវត្ថិភាពចំណីអាហារ និងការផ្តល់អាហារតាមសាលារៀន ៥) អប់រំអំពីសុខភាពសិក្សា និងគន្លងប្រក្រតីភាពថ្មី ដោយអនុវត្តតាមខ្លឹមសាររបស់កម្មវិធីសិក្សាមុខវិជ្ជាសុខភាពសិក្សា ការហាត់ប្រាណ និងលេងកីឡា។

- បានរៀបចំបរិយាកាសសាលារៀនប្រកបដោយសុវត្ថិភាព សុវត្ថិភាពចំណីអាហារ បន្ទប់សុខភាព ទឹកស្អាត មន្ទីរពិសោធន៍ បណ្ណាល័យ ជាដើម។

### 2. កម្មវិធីផ្តល់អាហារនៅតាមសាលារៀន

- បានអនុវត្តកម្មវិធីផ្តល់អាហារនៅតាមសាលារៀន ដោយប្រើប្រាស់ផលិតផលកសិកម្មសហគមន៍។ ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ សិស្សសរុបចំនួន ៣៧០,០០០ នាក់ បានទទួលអត្ថប្រយោជន៍ពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន។

### 3. កម្មវិធីអាហារូបករណ៍

- ចំពោះកម្មវិធីអាហារូបករណ៍នៅថ្នាក់បឋមសិក្សា ក្រសួងបានពង្រីកការអនុវត្តរបស់ខ្លួនជាបន្តបន្ទាប់។ គិតត្រឹមឆ្នាំ២០២៥ សិស្សក្រីក្រប្រមាណ ៣៣០,០០០នាក់ បានទទួលអាហារូបករណ៍ចំនួន ២៤០,០០០រៀលក្នុងមួយឆ្នាំ តាមរយៈថវិកាកញ្ចប់ឧបត្ថម្ភគ្រួសារ។

## 2.5.4. ការកែលម្អគុណភាពគ្រូបង្រៀនបឋមសិក្សា

- បានបង្កើតស្តង់ដាគុណវុឌ្ឍិគ្រូបង្រៀន និងសមត្ថភាពគ្រូបង្រៀន។
- បានដំឡើងប្រព័ន្ធអប់រំគ្រូបង្រៀនពី ១២+២ ទៅ ១២+៤ (សមមូលនឹងសញ្ញាបត្របរិញ្ញាបត្រ) ឬ បរិញ្ញាបត្រ+១ សម្រាប់គ្រូបឋមសិក្សា។
- បានបញ្ចូលកញ្ចប់សម្ភារថ្នាក់ដំបូងទៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន និងការធ្វើវិក្រឹតការគ្រូ និងក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ។
- បានកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈ នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូរួមទាំងបណ្ណាល័យឌីជីថល ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់ការបណ្តុះបណ្តាល។
- បានបណ្តុះបណ្តាលគ្រូបង្រៀនកិច្ចសន្យាដែលមានស្រាប់ ដើម្បីឱ្យមានសមត្ថភាពជាគ្រូបង្រៀនបឋមសិក្សា។
- បានផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) លើការបង្រៀនថ្នាក់ដំបូង (EGL), វិធីសាស្ត្របង្រៀនថ្មី, វិធីសាស្ត្របង្វឹក, ការគ្រប់គ្រងថ្នាក់រៀន និងគរុកោសល្យសតវត្សទី២១ សម្រាប់គ្រូបង្រៀនដែលកំពុងបម្រើការងារ។
- ពង្រឹងសមត្ថភាពគ្រូឧទ្ទេស ដោយត្រូវមានគុណវុឌ្ឍិអប្បបរមា បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ។
- កែសម្រួលលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសគ្រូ ដោយផ្តល់អាទិភាពដល់សិស្សដែលមាននិទ្ទេស A, B, និង C ដើម្បីបម្រើការជាគ្រូបង្រៀន។
- បានធ្វើបច្ចុប្បន្នកម្មផែនការសកម្មភាពសម្រាប់គោលនយោបាយគ្រូបង្រៀន ១) ទាក់ទាញបេក្ខជនដែលមានសមត្ថភាពឱ្យធ្វើជាគ្រូបង្រៀន, ២) កែលម្អការបណ្តុះបណ្តាលគរុនិស្សិត, ៣) ពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ, និង ៤) កែលម្អលក្ខខណ្ឌការងារសម្រាប់គ្រូបង្រៀន។

- ភ្ជាប់ស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀនជាមួយសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ និងធានាស្តង់ដានៃស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀន។
- លើកកម្ពស់វប្បធម៌ស្រាវជ្រាវក្នុងចំណោមគ្រូឧទ្ទេស និងគរុនិស្សិត។
- កែលម្អវិធីសាស្ត្របង្រៀន ការពិសោធ និងការស្រាវជ្រាវសតវត្សទី២១ ដែលលើកកម្ពស់សមត្ថភាពសកលរបស់សិស្ស ដូចដែលបានវាស់វែងនៅក្នុងកម្មវិធី PISA។
- បង្កើនសមត្ថភាពគ្រូក្នុងការបង្រៀនអំណាននិងគណិតវិទ្យាថ្នាក់ដំបូង ព្រមទាំងភ្ជាប់ចំណេះដឹងទៅនឹងការដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅ។
- បានរៀបចំវគ្គសិក្សាអក្ខរកម្មឌីជីថលសម្រាប់គ្រូបង្រៀន (EdTech for Teachers) នៅតាមស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀន។
- បានដំឡើងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួនពីរទៅជា វិទ្យាស្ថានគរុកោសល្យ។

### 2.5.5. ការរក្សាភាពធន់នៃការសិក្សាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩

- ក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក្រសួងបានប្រើប្រាស់គ្រប់មធ្យោបាយដើម្បីធានាថាដំណើរការសិក្សានៅតែបន្ត ទោះបីជាសាលារៀនត្រូវបានបិទក៏ដោយ។ វិធានការទាំងនេះរួមមានៈ ការផលិតវីដេអូបង្រៀននិងរៀនដ៏សម្បូរបែប ការរៀបចំមេរៀន ឬសន្លឹកកិច្ចការសម្រាប់សិស្ស ការបង្កើតវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ការចែកចាយសម្ភារៈដល់សហគមន៍សម្រាប់ការរៀនសូត្រនៅផ្ទះ និងការផ្សាយតាមទូរទស្សន៍ជាប្រចាំជារៀងរាល់ថ្ងៃ។

### 2.5.6. ពង្រឹងអភិបាលកិច្ចសាលារៀន

- អនុវត្តស្តង់ដាសាលារៀនគំរូ ដោយផ្តោតលើ ក) សាលារៀនមានគណនេយ្យភាពចំពោះសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀនគំរូ ខ) សាលារៀនមានស្វ័យភាពក្នុងផែនការកែលម្អសាលារៀន និងផ្តល់ការកសាងសមត្ថភាពជាប្រចាំដល់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន គ) សិស្សត្រូវធ្វើតេស្តស្តង់ដាដោយមានតម្លាភាព និងយុត្តិធម៌ ដើម្បីកែលម្អការបង្រៀន និងការរៀន, ជួយដល់សិស្សដែលមានលទ្ធផលទាប, និងផ្តល់ព័ត៌មានដល់ឪពុកម្តាយ និងសហគមន៍។ ឃ) គ្រូបង្រៀនប្រើប្រាស់លទ្ធផលនៃការវាយតម្លៃ ដើម្បីកែលម្អការបង្រៀន និងអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ ង) ឪពុកម្តាយ និងសហគមន៍ត្រូវចូលរួម និងគាំទ្រដល់ការអភិវឌ្ឍសាលារៀន។ ដំណើរការសាលារៀនអាស្រ័យលើការអនុវត្តវិធានការដូចខាងក្រោមៈ
    - **ពង្រឹងការគ្រប់គ្រងសាលារៀនៈ** រួមទាំងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហគមន៍ និងមាតាបិតា ដើម្បីដោះស្រាយបញ្ហាប្រឈមនានានៅក្នុងសាលារៀន និងធានាបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ សាលារៀនត្រូវពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិអប់រំ

និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសាលារៀន រៀបចំផែនការគ្រប់គ្រងគ្រូបង្រៀនតាមមុខវិជ្ជា (ដោះស្រាយបញ្ហាខ្វះគ្រូ) ផ្តល់សម្ភារបង្រៀន និងវិធីសាស្ត្របង្រៀន។

- **រៀបចំផែនការអភិវឌ្ឍសាលារៀន៖** សាលារៀនត្រូវកំណត់ចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ។ សាលារៀនត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ និងផែនការអភិវឌ្ឍសាលារៀន (៦ឆ្នាំ, ៣ឆ្នាំ, និង ១ឆ្នាំ) រួមទាំងកម្មវិធីបំប៉នសិស្សរៀនយឺតដោយមានការគាំទ្រពីសហគមន៍។
- **ការធ្វើតេស្តស្តង់ដា៖** លទ្ធផលតេស្តស្តង់ដាដើមឆ្នាំ ប្រឡងប្រចាំខែ ប្រឡងប្រចាំត្រីមាស និងតេស្តចុងឆ្នាំ ត្រូវប្រើប្រាស់ដើម្បីកែលម្អការរៀន និងការបង្រៀន ជាពិសេសដើម្បីជួយសិស្សរៀនយឺត តាមរយៈការកែលម្អវិធីសាស្ត្របង្រៀន ការអប់រំវិន័យវិជ្ជមាន និងការប្រឹក្សាគរុកោសល្យ។
- **ការវាយតម្លៃបុគ្គលិក៖** គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តប្រចាំឆ្នាំជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីធានាបានគណនេយ្យភាពចំពោះសហគមន៍។

# ជំពូកទី៣ ភាពជាពលរដ្ឋសកល

## 3.1. សេចក្តីផ្តើម

ជំពូកនេះបង្ហាញពីការយល់ឃើញរបស់គ្រូ និងសិស្សអំពីភាពជាពលរដ្ឋសកល។ ព័ត៌មានពេញលេញស្តីពីបញ្ញត្តិ (Conceptualization) និងការប្រើប្រាស់ (Operationalization) ភាពជាពលរដ្ឋសកលមាននៅក្នុងក្របខ័ណ្ឌភាពជាពលរដ្ឋសកល SEA-PLM ឆ្នាំ២០១៩។ នៅក្នុងរបាយការណ៍នេះ ផ្តោតលើលទ្ធផលសំខាន់ពីរ រួមមាន ឥរិយាបថ និងគុណតម្លៃទាក់ទងនឹងភាពជាពលរដ្ឋសកល និងអាកប្បកិរិយា និងជំនាញទាក់ទងនឹងភាពជាពលរដ្ឋសកល។ យោងតាមក្របខ័ណ្ឌភាពជាពលរដ្ឋសកល ពលរដ្ឋសកលត្រូវបានឱ្យនិយមន័យថា៖ *ពលរដ្ឋសកលឱ្យតម្លៃ និងយល់ពីទំនាក់ទំនងទៅវិញទៅមកនៃជីវិតទាំងអស់នៅលើភពផែនដី។ ពួកគេធ្វើសកម្មភាព និងប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដោយយល់ដឹងពីទំនាក់ទំនងទៅវិញទៅមកនេះ ដើម្បីធ្វើឱ្យពិភពលោកក្លាយជាកន្លែងដែលមានសន្តិភាព យុត្តិធម៌ សុវត្ថិភាព និងនិរន្តរភាព។*

លទ្ធផលនៅក្នុងផ្នែកនេះ ក៏ផ្តល់ឱ្យបណ្តាប្រទេស និងភាគីពាក់ព័ន្ធនូវព័ត៌មានបរិមាណ ដើម្បីជួយក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG 4.7។ គោលបំណងនៃ SDG 4.7 គឺដើម្បី "ធានាថាសិស្សទាំងអស់ទទួលបានចំណេះដឹង និងបំណិនចាំបាច់ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងរបៀបរស់នៅប្រកបដោយនិរន្តរភាព សិទ្ធិមនុស្ស សមភាពយេនឌ័រ ការលើកកម្ពស់វប្បធម៌សន្តិភាព អហិង្សា ភាពជាពលរដ្ឋសកល ការឱ្យតម្លៃចំពោះភាពចម្រុះនៃវប្បធម៌និងការរួមចំណែករបស់វប្បធម៌ ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព"។

## 3.2. ការយល់ឃើញចំពោះការអប់រំភាពជាពលរដ្ឋសកល

### 3.2.1. ការយល់ឃើញរបស់សិស្សអំពីប្រធានបទភាពជាពលរដ្ឋសកល ដែលបានរៀននៅសាលារៀន

រូប 3.1 បង្ហាញពីភាគរយសិស្សដែលបានលើកឡើងថាពួកគេបានរៀនអំពីប្រធានបទភាពជាពលរដ្ឋសកលនៅក្នុងសាលារៀន។ ប្រធានបទទាក់ទងនឹងបញ្ហាបរិស្ថានដែលសិស្សកម្ពុជាភាគច្រើនបានរៀនរួមមានការការពារបរិស្ថាន (៧៣.៤%) និងការប្រែប្រួលអាកាសធាតុ (៦៧.៧%)។ ចំណែកឯប្រធានបទបរិស្ថានដែលសិស្សតិចតួចបានរៀន រួមមាន ការបំពុលបរិស្ថាននៅក្នុងប្រទេសកម្ពុជា (៤២.១%) និងការបំពុលបរិស្ថាននៅប្រទេសដទៃ (៣៨.៧%)។ ប្រធានបទអំពីសង្គម និងពលរដ្ឋ

ស្ថិតនៅកម្រិតមធ្យមផងដែរ ដោយមាន សិស្ស ៥៩.១% បានលើកឡើងថាបានរៀនពីវិធីដោះស្រាយបញ្ហាដោយសន្តិវិធីជាមួយមិត្តរួមថ្នាក់ និងការជួយដោះស្រាយបញ្ហានៅក្នុងសហគមន៍ (៥០%)។

*រូប 3.1. ភាគរយសិស្សដែលបានលើកឡើងថាបានរៀនខ្លះៗ ឬច្រើនអំពីប្រធានបទខាងក្រោមនៅសាលារៀន*




## 3.2.2. ឥរិយាបថរបស់សិស្សអំពីបញ្ហាសង្គម

សិស្សត្រូវបានសួរអំពីកម្រិតយល់ស្របចំពោះប្រយោគដែលទាក់ទងនឹងបញ្ហាសង្គម។ សិស្សភាគច្រើនបានយល់ស្របចំពោះបញ្ហាសង្គម រួមមាន កាតព្វកិច្ចរបស់ប្រជាជនក្នុងការការពារបរិស្ថាន (៨៩.០%), ការយល់ដឹងពីយុត្តិធម៌សង្គម (៨៧.៦%), ការផ្តល់តម្លៃនិងការយល់ពីវប្បធម៌របស់មនុស្សជាតិ (៨៣.៧%), ឱកាសទទួលបានការអប់រំដូចគ្នាសម្រាប់កុមារគ្រប់រូប (៨២.៣%) ជាដើម (រូប 3.2)។

*រូប 3.2. ភាគរយសិស្សដែលយល់ស្រប ឬយល់ស្របទាំងស្រុង ចំពោះប្រយោគខាងក្រោម*



### 3.2.3. ការព្រួយបារម្ភរបស់សិស្សចំពោះបញ្ហាទាក់ទងនឹងភាពជាពលរដ្ឋសកល

សិស្សកម្ពុជាមានការព្រួយបារម្ភអំពីបញ្ហាទាក់ទងនឹងភាពជាពលរដ្ឋសកល។ សិស្សភាគច្រើនមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបាត់បង់ធនធានធម្មជាតិ (៧៦.៥%), ការប្រែប្រួលអាកាសធាតុ (៧៥.៩%), ការផុតពូជរុក្ខជាតិ (៧៥.៧%), កង្វះទឹក (៧៥.០%), ការផុតពូជសត្វ (៧៤.៧%) ជាដើម (រូប 3.3)។ គេរកឃើញថាមានទំនាក់ទំនងគ្នាគួរឱ្យកត់សម្គាល់រវាងការព្រួយបារម្ភរបស់សិស្សចំពោះបញ្ហាសកល ជាមួយលទ្ធផលរបស់សិស្ស ដោយមេគុណទំនាក់ទំនង (r) ០.២៥ ចំពោះអំណាន និង ០.២៣ ចំពោះគណិតវិទ្យា។ នេះមានន័យថាសិស្សពូកែមានការព្រួយបារម្ភអំពីបញ្ហាទាក់ទងនឹងភាពជាពលរដ្ឋសកលជាងសិស្សខ្សោយ។

*រូប 3.3. ភាគរយសិស្សដែលបានលើកឡើងថាមានការព្រួយបារម្ភ ឬព្រួយបារម្ភខ្លាំងណាស់ចំពោះបញ្ហាខាងក្រោម*




### 3.2.4. អាកប្បកិរិយាជាពលរដ្ឋល្អរបស់សិស្ស

រូប 3.4 បង្ហាញពីភាគរយសិស្សកម្ពុជាថ្នាក់ទី៩ ដែលបានលើកឡើងថាពួកគេនឹងធ្វើសកម្មភាពទាក់ទងនឹងអាកប្បកិរិយារបស់ពលរដ្ឋល្អ។ សិស្សភាគច្រើននឹងចូលរួមសកម្មភាពទាក់ទងពលរដ្ឋល្អ ដូចជាការចូលរួមកែលម្អបរិស្ថានសាលារៀន(៧៨.៨%), ការហាមឃាត់បោះសំរាមចោលផ្ដេសផ្ដាស(៧២.៥%), ការចូលរួមជាក្រុមដើម្បីជួយការពារបរិស្ថាន (៧០.៩%), ការលើកទឹកចិត្តអ្នកដទៃឱ្យចេះជួយការពារបរិស្ថាន (៧០.៦%) ជាដើម។

*រូប 3.4. ភាគរយសិស្សដែលលើកឡើងថាពួកគេប្រហែលនឹងធ្វើ ឬធ្វើសកម្មភាពទាំងនេះ*




## 3.3. ការយល់ឃើញ និងសមត្ថភាពរបស់គ្រូបង្រៀនទាក់ទងនឹងការអប់រំភាពជាពលរដ្ឋសកល

គ្រូបង្រៀនថ្នាក់ទី៥ តម្រូវឱ្យបំពេញកម្រងសំណួរគ្រូបង្រៀននៃរង្វាយតម្លៃ SEA-PLM ហើយសំណួរជាច្រើនទាក់ទងនឹងភាពជាពលរដ្ឋសកល។ គ្រូបង្រៀនបានបង្ហាញពីការយល់ឃើញអំពីសារៈសំខាន់នៃប្រធានបទភាពជាពលរដ្ឋសកលសម្រាប់សិស្សដើម្បីរៀននៅសាលារៀន ក៏ដូចជាបំណិន និងតម្លៃភាពជាពលរដ្ឋសកលដែលមានសារៈសំខាន់សម្រាប់សិស្ស ព្រមទាំងការបណ្តុះបណ្តាលលើខ្លឹមសារភាពជាពលរដ្ឋសកល និងទំនុកចិត្តក្នុងការបង្រៀនប្រធានបទអំពីភាពជាពលរដ្ឋសកល។

### 3.3.1. ឥរិយាបថរបស់គ្រូបង្រៀនចំពោះការរៀនភាពជាពលរដ្ឋសកលរបស់សិស្សនៅសាលារៀន

គ្រូបង្រៀនត្រូវបានសួរអំពីសារៈសំខាន់របស់ប្រធានបទខាងក្រោមដែលទាក់ទងនឹងភាពជាពលរដ្ឋសកលសម្រាប់សិស្សថ្នាក់ទី៥ រៀននៅសាលា។ គ្រូបង្រៀនភាគច្រើនយល់ឃើញថាប្រធានបទទាំងអស់ខាងក្រោមមានសារៈសំខាន់សម្រាប់សិស្សដែលត្រូវសិក្សានៅសាលារៀន រួមមាន ការការពារបរិស្ថាន (១០០%), ការដោះស្រាយដោយសន្តិវិធីជាមួយមិត្តរួមថ្នាក់ (៩៨.១%), ការដោះស្រាយបញ្ហានៅក្នុងសហគមន៍ (៩៧.៥%), បញ្ហាខាងក្រៅដែលជះឥទ្ធិពលមកលើប្រទេសកម្ពុជា (៩៧.០%) ជាដើម (រូប 3.5)។

*រូប 3.5. ភាគរយគ្រូបង្រៀនដែលយល់ឃើញថាប្រធានបទនីមួយៗខាងក្រោមមានសារៈសំខាន់ ឬសារៈសំខាន់ណាស់សម្រាប់សិស្សថ្នាក់ទី៥ ក្នុងការរៀននៅសាលា*




## 3.3.2. អាកប្បកិរិយារបស់គ្រូបង្រៀនអំពីបំណិន និងគុណតម្លៃនៃភាពជាពលរដ្ឋសកលរបស់សិស្ស

គ្រូបង្រៀនភាគច្រើនយល់ឃើញថាបំណិន និងគុណតម្លៃខាងក្រោមទាំងអស់មានសារៈសំខាន់ឬសារៈសំខាន់ណាស់សម្រាប់សិស្សត្រូវអភិវឌ្ឍ។ បំណិន និងគុណតម្លៃទាំងនោះរួមមាន ការមានអារម្មណ៍ថាខ្លួនមានទំនាក់ទំនងជាមួយអ្នកដទៃ(១០០%), ការយល់ដឹងអំពីសមភាព (៩៩.៧%), ការមានឆន្ទៈប្រឆាំងនឹងភាពអយុត្តិធម៌ (៩៩%), ការចូលរួមដោះស្រាយបញ្ហាវិសមភាព (៩៥.៦%), ការទទួលស្គាល់ថាមនុស្សមានភាពខុសគ្នា (៩៣.១%) ជាដើម (រូប 3.6)។

*រូប 3.6. ភាគរយគ្រូបង្រៀនដែលយល់ឃើញថាបំណិន និងគុណតម្លៃខាងក្រោមមានសារៈសំខាន់ឬសារៈសំខាន់ណាស់សម្រាប់សិស្សត្រូវអភិវឌ្ឍ*




## 3.3.3. ការបណ្តុះបណ្តាលទាក់ទងនឹងភាពជាពលរដ្ឋសកល

គ្រូបង្រៀនភាគច្រើនបានលើកឡើងថាកម្មវិធីបណ្តុះបណ្តាលគ្រូបានបណ្តុះបណ្តាលពួកគាត់បានយ៉ាងល្អ សម្រាប់ត្រៀមបង្រៀនសិស្សលើប្រធានបទភាពជាពលរដ្ឋសកលខាងក្រោម រួមមាន សិទ្ធិកុមារ (៩៧.២%), ការអភិវឌ្ឍប្រកបដោយចីរភាព (៩៧.០%), ការការពារបរិស្ថាន (៩២.៥%), ការដោះស្រាយជម្លោះ (៩០.៩%) ជាដើម (រូប 3.7)។

*រូប 3.7. ភាគរយគ្រូបង្រៀនដែលបានលើកឡើងថាកម្មវិធីបណ្ដុះបណ្ដាលគ្រូបានបណ្ដុះបណ្ដាលពួកគាត់យ៉ាងល្អ ឬល្អណាស់ដើម្បីបង្រៀនខ្លឹមសារទាក់ទងនឹងភាពជាពលរដ្ឋសកល*




### 3.3.4. ទំនុកចិត្តក្នុងការបង្រៀនប្រធានបទស្ដីពីភាពជាពលរដ្ឋសកល

គ្រូបង្រៀនភាគច្រើន មានភាពជឿជាក់ក្នុងការបង្រៀនខ្លឹមសារស្ដីពីភាពជាពលរដ្ឋសកល ដល់សិស្សថ្នាក់ទី៥ ដែលប្រធានបទទាំងនោះរួមមាន សិទ្ធិកុមារ (៩៩.៤%), ការអភិវឌ្ឍប្រកបដោយចីរភាព (៩៨.៦%), ការដោះស្រាយជម្លោះ (៩៤.៥%), ការគោរពភាពចម្រុះ (៩១.០%), ព្រឹត្តិការណ៍ថ្មីៗក្នុងប្រទេស (៩០.៣%) ជាដើម (រូប 3.8)។

*រូប 3.8. ភាគរយគ្រូបង្រៀនដែលមានការជឿជាក់ និងជឿជាក់ខ្លាំងក្នុងការបង្រៀនខ្លឹមសារស្ដីពីភាពជាពលរដ្ឋសកល*



# ជំពូកទី៤ ការវិភាគកត្តាដែលរួមចំណែកដល់លទ្ធផលសិក្សារបស់សិស្ស

## 4.1. សេចក្តីផ្តើម

ជំពូកនេះត្រូវបានរៀបចំឡើងដោយផ្អែកលើក្របខ័ណ្ឌគំនិតនៃវង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ ដែលផ្តោតលើគំរូ ធាតុចូល-ដំណើរការ-ធាតុចេញ នៃប្រសិទ្ធភាពសាលារៀន។ ក្របខ័ណ្ឌនេះបង្ហាញពីរបៀបដែលលទ្ធផលសិក្សារបស់សិស្សត្រូវបានជះឥទ្ធិពលដោយអន្តរកម្មរវាងកត្តាផ្សេងៗ ដំណើរការ និងសមិទ្ធផល។ ដំណាក់កាលដំបូងជាសាវតាររបស់សិស្ស និងគ្រួសារ ហើយដំណាក់កាលដំណើរការផ្តោតលើបរិស្ថានសាលារៀន និងថ្នាក់រៀន។ ជំពូកនេះបង្ហាញពីការវិភាគកត្តាដែលរួមចំណែកដល់លទ្ធផលសិក្សារបស់សិស្ស។

## 4.2. កត្តាសិស្ស

ផ្នែកនេះពិពណ៌នាអំពីលក្ខណៈសិស្សដែលមានទំនាក់ទំនងនឹងលទ្ធផលសិក្សារបស់សិស្ស។ លក្ខណៈទាំងនេះរួមមាន អាយុ ការរៀនត្រួតថ្នាក់ ការរៀនថ្នាក់មត្តេយ្យ ការរំពឹងទុករបស់ឪពុកម្តាយចំពោះការអប់រំរបស់កូន កម្រិតអប់រំរបស់ឪពុកម្តាយ អាកប្បកិរិយារបស់សិស្ស សកម្មភាពសិក្សានៅផ្ទះក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩ និងសិស្សមានពិការភាព។

### 4.2.1. អាយុសិស្ស

ប្រៀបធៀបរវាងឆ្នាំ២០១៩ និង ២០២៤ ភាគរយសិស្សដែលមានអាយុលើសបានថយចុះពី ៣៦% ទៅ ២៩% ខណៈពេលដែលភាគរយសិស្សដែលគ្រប់អាយុបានកើនឡើងពី ៦៤% ទៅ ៧១% ដែលឆ្លុះបញ្ចាំងពីការចុះឈ្មោះចូលរៀនរបស់សិស្សកាន់តែប្រសើរ និងកាត់បន្ថយការរៀនត្រួតថ្នាក់ (សូមមើលរូប 4.1)។ សិស្សគ្រប់អាយុទទួលបានពិន្ទុខ្ពស់ជាងសិស្សលើសអាយុ ៨ពិន្ទុ ទាំងអំណាន និងគណិតវិទ្យា (សូមមើលរូប 4.2)។ ទោះជាយ៉ាងណាក៏ដោយ គម្លាតលទ្ធផលរបស់សិស្សតាមក្រុមអាយុត្រូវបានកាត់បន្ថយនៅរវាងឆ្នាំ២០១៩ និង២០២៤។ លទ្ធផលនេះបានបង្ហាញថាការគាំទ្រដល់សិស្សដែលលើសអាយុមានផលជះ ដល់ការរៀនសូត្ររបស់ពួកគេ។

*រូប 4.1.ភាគរយសិស្សកម្ពុជាថ្នាក់ទី៥ តាមក្រុមអាយុសិស្សនៅឆ្នាំ២០១៩ និង២០២៤*




*រូប 4.2. លទ្ធផលអំណាន និងគណិតវិទ្យាតាមក្រុមអាយុសិស្សនៅឆ្នាំ២០១៩ និង២០២៤*




## 4.2.2. ការរៀនថ្នាក់មត្តេយ្យ

រវាងឆ្នាំ២០១៩ និង ២០២៤ ភាគរយសិស្សដែលចូលរៀនថ្នាក់មត្តេយ្យមានរយៈពេល ១ឆ្នាំ ឬច្រើនជាងនេះ បានកើនឡើងពី ៥៨% ដល់ ៨០% ដែលឆ្លុះបញ្ចាំងពីចំនួនសិស្សកម្ពុជាដែលឆ្លងកាត់មត្តេយ្យសិក្សាកាន់តែច្រើន មុនពេលចូលរៀននៅសាលាបឋមសិក្សា (សូមមើលរូប 4.3)។ សិស្សដែល

បានចូលរៀនថ្នាក់មត្តេយ្យ មានលទ្ធផលល្អប្រសើរជាងសិស្សមិនបានចូលរៀន ទាំងអំណាន និង គណិតវិទ្យា (SEA-PLM ឆ្នាំ២០១៩ និង ២០២៤) (សូមមើលរូប 4.4)។

*រូប 4.3. ភាគរយសិស្សកម្ពុជាថ្នាក់ទី៥ តាមស្ថានភាពនៃការចូលរៀនថ្នាក់មត្តេយ្យនៅឆ្នាំ២០១៩ និង២០២៤*




*រូប 4.4. លទ្ធផលអំណាន និងគណិតវិទ្យាតាមស្ថានភាពនៃការចូលរៀនថ្នាក់មត្តេយ្យនៅឆ្នាំ២០១៩ និង២០២៤*




### 4.2.3. ការរៀនត្រួតថ្នាក់

កម្រងសំណួរសិស្សរបស់រង្វាយតម្លៃ SEA-PLM បានឱ្យសិស្សរាយការណ៍ថាតើពួកគេបានរៀនត្រួតថ្នាក់យ៉ាងតិចមួយកម្រិតថ្នាក់ ដែរឬទេ។ លទ្ធផលបានបង្ហាញថា សិស្សកម្ពុជា ៣៧.៣% បានលើកឡើងថាបានរៀនត្រួតថ្នាក់យ៉ាងតិចមួយកម្រិតថ្នាក់។ ក្នុងចំណោមសិស្សទាំងនេះ សិស្សប្រុសរៀនត្រួតថ្នាក់ច្រើនជាងសិស្សស្រី (សិស្សប្រុស ៤២.៣% និងសិស្សស្រី ៣២.៣%) (សូមមើលរូប 4.5)។

*រូប 4.5. ភាគរយសិស្សថ្នាក់ទី៥ ដែលបានរៀនត្រួតថ្នាក់នៅឆ្នាំ២០២៤*




រូប 4.6 បានបង្ហាញថាសិស្សដែលមិនធ្លាប់រៀនត្រួតថ្នាក់ រៀនពូកែជាងសិស្សដែលធ្លាប់រៀនត្រួតថ្នាក់ លើអំណាន និងគណិតវិទ្យា។ ភាពខុសគ្នាគឺ ១២ ពិន្ទុ ចំពោះអំណាន និង ១១ ពិន្ទុ ចំពោះគណិតវិទ្យា។ លទ្ធផលទាំងនេះបង្ហាញថា ការរៀនត្រួតថ្នាក់នាំឱ្យមានលទ្ធផលទាប។

*រូប 4.6. លទ្ធផលអំណាន និងគណិតវិទ្យាតាមស្ថានភាពនៃការរៀនត្រួតថ្នាក់នៅឆ្នាំ២០២៤*



### 4.2.4. កម្រិតអប់រំរបស់ឪពុកម្ដាយ

សិស្សភាគច្រើនមកពីគ្រួសារដែលឪពុកម្ដាយមានកម្រិតអប់រំទាប។ សិស្ស ៣៥.៤% និង ៣០.៩% បានលើកឡើងថាឪពុកម្ដាយរបស់ពួកគេបានបញ្ចប់ការសិក្សាត្រឹមតែបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិរៀងគ្នា។ ទន្ទឹមនឹងនេះ សិស្ស ១៩.៥% បានលើកឡើងថា ឪពុកម្ដាយរបស់ពួកគេបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ ហើយមានតែ ៩.០% ប៉ុណ្ណោះដែលនិយាយថាឪពុកម្ដាយរបស់ពួកគេបានបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា ដូចជាបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិត។ សិស្ស ១.៨% បានលើកឡើងថា ឪពុកម្ដាយរបស់ពួកគេមានការបណ្ដុះបណ្ដាលវិជ្ជាជីវៈឬបរិញ្ញាបត្ររង។

*រូប 4.7. ភាគរយសិស្សថ្នាក់ទី៥ តាមកម្រិតអប់រំរបស់ឪពុកម្ដាយ*




### 4.2.5. ការរំពឹងទុករបស់ឪពុកម្ដាយចំពោះការអប់រំរបស់កូន

សិស្សភាគច្រើនជឿថាឪពុកម្ដាយរបស់ពួកគេមានសេចក្ដីប្រាថ្នាខ្ពស់ចំពោះការអប់រំរបស់ពួកគេ។ សិស្ស ៤២.៦% បានលើកឡើងថាឪពុកម្ដាយរបស់ពួកគេរំពឹងថាពួកគេនឹងបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា ឬខ្ពស់ជាងនេះ ហើយសិស្ស ៤១.៥% បានបង្ហាញថាឪពុកម្ដាយរបស់ពួកគេចង់ឱ្យពួកគេបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ។ ទន្ទឹមនឹងនេះ សិស្ស ៨.២% បាននិយាយថាឪពុកម្ដាយរបស់ពួកគេរំពឹងថាពួកគេនឹងបន្តការបណ្ដុះបណ្ដាលវិជ្ជាជីវៈឬក្រោយមធ្យមសិក្សា និងសិស្ស ៦.៣% បានលើកឡើងពីការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ហើយមានតែ សិស្ស ១.៤% ប៉ុណ្ណោះដែលនិយាយថាការអប់រំបឋមសិក្សាគឺជាកម្រិតដែលពួកគេរំពឹងទុក។

*រូប 4.8. ភាគរយសិស្សថ្នាក់ទី៥ តាមការរំពឹងទុករបស់ឪពុកម្ដាយចំពោះការអប់រំរបស់កូនពួកគាត់*




### 4.2.6. ការយល់ឃើញរបស់គ្រូបង្រៀនអំពីបញ្ហាដែលប៉ះពាល់ដល់ការសិក្សារបស់សិស្ស

គ្រូបង្រៀនតម្រូវឱ្យកំណត់កត្តាចម្បងៗមួយចំនួនដែលប៉ះពាល់ដល់ការសិក្សារបស់សិស្សថ្នាក់ទី៥ ក្នុងកម្រិតមធ្យម ឬកម្រិតខ្លាំង (រូប 4.9)។ គ្រូបង្រៀនថ្នាក់ទី៥ ចំនួន ៥៦% បានលើកឡើងថា បញ្ហាដែលកើតមានញឹកញាប់បំផុតគឺសិស្សខ្វះចំណេះដឹង ឬជំនាញមូលដ្ឋាន បន្ទាប់មកគឺសិស្សខ្វះចំណាប់អារម្មណ៍ (៣៣.៣%), សុខភាពមិនល្អ (២១.២%), អវត្តមាន (២០.៦%), អាកប្បកិរិយារំខានក្នុងថ្នាក់ (១៨.៤%), ឃ្លានអាហារ (១៥.៨%), និងការគេងមិនគ្រប់គ្រាន់ (១៣.៨%)។

*រូប 4.9. ភាគរយនៃបញ្ហាដែលប៉ះពាល់ដល់ការសិក្សារបស់សិស្សក្នុងកម្រិតមធ្យម ឬកម្រិតខ្លាំង យោងតាមការលើកឡើងរបស់គ្រូបង្រៀន*



### 4.2.7. ការយល់ឃើញរបស់គ្រូបង្រៀនចំពោះអាកប្បកិរិយារបស់សិស្ស

ដោយផ្អែកលើការរាយការណ៍របស់គ្រូបង្រៀន ឥរិយាបថរបស់សិស្សថ្នាក់ទី៥ កម្ពុជា គឺវិជ្ជមានគ្រប់ទិដ្ឋភាពទាំងអស់។ គ្រូបង្រៀនបានលើកឡើងថា សិស្សភាគច្រើនបង្ហាញឥរិយាបថវិជ្ជមាននៅក្នុងសាលារៀន ជាពិសេស សិស្ស ៩៦% រក្សាទំនាក់ទំនងល្អជាមួយគ្រូបង្រៀន និងបុគ្គលិកសាលារៀន ហើយសិស្ស ៩៤% គោរពតាមវិន័យសាលារៀន និងមានឥរិយាបថល្អនៅក្នុងបរិវេណសាលារៀន។ លើសពីនេះ សិស្ស ៩១% និយាយជាវិជ្ជមានអំពីសាលារៀនរបស់ពួកគេ ខណៈដែលសិស្ស ៨៥% បង្ហាញការយកចិត្តទុកដាក់ចំពោះសម្ភារៈ និងសម្ភាររូបវន្តសាលារៀន។

*រូប 4.10. ភាគរយបញ្ហាអាកប្បកិរិយារបស់សិស្សយោងតាមការលើកឡើងរបស់គ្រូបង្រៀនថ្នាក់ទី៥*




### 4.2.8. ការសិក្សានៅផ្ទះក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩

ទាក់ទងនឹងសកម្មភាពដែលសិស្សបានធ្វើក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩ សិស្សជាច្រើនបានអនុវត្តតិចតួចចំពោះសកម្មភាពសិក្សាឌីជីថល (សូមមើលរូប 4.11)។ មានតែសិស្សមួយចំនួនតូចប៉ុណ្ណោះ ដែលបានលើកឡើងថាបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពឌីជីថលទាំងនេះជាប្រចាំ ដោយ មានសិស្ស ២២.២% បានប្រើប្រាស់អ៊ីនធឺណិតជាញឹកញាប់សម្រាប់កិច្ចការសាលា និងសិស្ស ១៩.២% បានប្រើប្រាស់វាជាប្រចាំសម្រាប់ការសិក្សាពីផ្ទះ។ សិស្សភាគច្រើនបានលើកឡើងថា ពួកគេមិនដែលបានប្រើប្រាស់អ៊ីនធឺណិតក្នុងការចែករំលែកព័ត៌មានផ្ទាល់ខ្លួននៅលើគេហទំព័រសាធារណៈ ឬប្រព័ន្ធផ្សព្វផ្សាយសង្គម (៥៤.៩%), មិនដែលគិតអំពីថាតើគេហទំព័រណាមួយគួរឱ្យទុកចិត្តឬទេ (៤៦.១%), ឬមិនដែលបញ្ចេញមតិរបស់អ្នកដទៃលើការបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយសង្គម (៥៣.៧%)។

*រូប 4.11. ភាគរយសិស្សថ្នាក់ទី៥ តាមសកម្មភាពដែលពួកគេបានធ្វើនៅផ្ទះក្នុងអំឡុងពេលមានជំងឺរាតត្បាត កូវីដ-១៩ នៅឆ្នាំ២០២៤*




សិស្សថ្នាក់ទី៥ ក៏ត្រូវបានសួរអំពីសកម្មភាពដែលពួកគេបានធ្វើនៅផ្ទះក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩ (សូមមើលរូប 4.12)។ ទិន្នន័យបង្ហាញថា សិស្សជាច្រើនប្រឈមមុខនឹងការទទួលខុសត្រូវក្នុងគ្រួសារ និងធនធានសិក្សានៅមានកម្រិត នៅពេលដែលសាលារៀនត្រូវបានបិទ។ សិស្សជាងពាក់កណ្តាល (៥៥.៩%) បានលើកឡើងថាពួកគេតែងតែជួយគ្រួសាររបស់ពួកគេធ្វើការងារផ្ទះ ដែលបង្ហាញថា ភារកិច្ចក្នុងផ្ទះគឺជាផ្នែកមួយទូទៅនៃជីវិតប្រចាំថ្ងៃរបស់ពួកគេ។ លើសពីនេះសិស្ស ២៧.០% តែងតែមើលថែសមាជិកគ្រួសារដែលឈឺ ឬមានវ័យចំណាស់ ហើយសិស្ស ២៤.៥% តែងតែមើលថែប្អូនៗ។ លើសពីនេះសិស្ស ១៦.០% មានអារម្មណ៍ថាពួកគេមិនមានអ្វីដែលពួកគេត្រូវការដើម្បីធ្វើកិច្ចការសាលា ដែលបង្ហាញថាសិស្សមួយចំនួនធំប្រឈមមុខនឹងការលំបាកក្នុងការទទួលបានសម្ភារសិក្សា ឬឯកសារសម្រាប់រៀននៅផ្ទះ។

*រូប 4.12. ភាគរយសិស្សថ្នាក់ទី៥ តាមសកម្មភាពនៅផ្ទះដែលពួកគេបានធ្វើក្នុងអំឡុងពេល មានជំងឺរាតត្បាតកូវីដ-១៩ នៅឆ្នាំ២០២៤*




## 4.2.9. សិស្សមានតម្រូវការអប់រំពិសេស

រូប 4.13 បង្ហាញពីភាគរយសិស្សកម្ពុជាថ្នាក់ទី៥ ដែលបានលើកឡើងថាបានជួបប្រទះនឹងការលំបាកក្នុងការរៀនសូត្រ ឬពិការភាពមុខងារផ្សេងៗ។ លទ្ធផលបង្ហាញថា សិស្សភាគច្រើនបានលើកឡើងថាមិនមានការលំបាកគួរឱ្យកត់សម្គាល់នៅក្នុងការសិក្សា ឬរាងកាយនោះទេ។ ឧទាហរណ៍ សិស្ស ៩៦.០% មិនមានការលំបាកក្នុងការដើរ ឬឡើងជណ្តើរទេ បន្ទាប់មកទៀតគឺសកម្មភាពថែទាំខ្លួនឯង (៩៥.៤%), ការនិយាយ (៩៥.៣%), ការស្តាប់ (៩២.៦%), ឬការមើល (៩១.៥%)។ ទោះជាយ៉ាងណាក៏ដោយ សិស្ស ២៣.៨% បានបង្ហាញថាមានការលំបាកបន្តិចបន្តួច ឬច្រើនជាងនេះក្នុងការគ្រប់គ្រងអាកប្បកិរិយា, ការរៀនឬការចងចាំរបស់របរ (២៦.៤%), ការផ្តោតអារម្មណ៍ និងផ្តោតការយកចិត្តទុកដាក់របស់ពួកគេ (២៧.៦%), និងការលំបាកក្នុងការសុំជំនួយពីគ្រូនៅពេលជួបប្រទះបញ្ហា (៣៨.២%)។

*រូប 4.13. ភាគរយសិស្សថ្នាក់ទី៥ តាមប្រភេទតម្រូវការអប់រំពិសេសនៅឆ្នាំ២០២៤*



## 4.3. កត្តាគ្រូបង្រៀន

ផ្នែកនេះពិពណ៌នាអំពីលក្ខណៈគ្រូបង្រៀន ដូចជាភេទគ្រូបង្រៀន អាយុ កម្រិតការអប់រំ ការបណ្តុះបណ្តាលសមត្ថភាព និងការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន។

### 4.3.1. ភេទគ្រូបង្រៀន

គ្រូបង្រៀនថ្នាក់ទី៥ ភាគច្រើននៅក្នុងប្រទេសកម្ពុជា ដែលបានចូលរួមក្នុងវង្វាយតម្លៃ SEA-PLM ឆ្នាំ ២០២៤ គឺជាស្ត្រី (៥៤%) និងបុរស (៤៦%)។ រូប 4.14 បង្ហាញពីលទ្ធផលរបស់សិស្សលើផ្នែកអំណាន និងគណិតវិទ្យា តាមភេទរបស់គ្រូបង្រៀន។ លទ្ធផលបង្ហាញថា សិស្សដែលបង្រៀនដោយអ្នកគ្រូរៀនពូកែជាងសិស្សដែលបង្រៀនដោយលោកគ្រូ ទាំងអំណាន និងគណិតវិទ្យា ដោយមានភាពខុសគ្នាស្មើនឹង ៦ ពិន្ទុ ទាំងពីរមុខវិជ្ជា។

*រូប 4.14. លទ្ធផលអំណាន និងគណិតវិទ្យាតាមភេទគ្រូបង្រៀននៅឆ្នាំ២០២៤*




### 4.3.2. អាយុគ្រូបង្រៀន

សិស្សថ្នាក់ទី៥ ៦៤.៥% រៀនជាមួយគ្រូដែលមានអាយុចន្លោះពី ២៥ ទៅ ៤៤ ឆ្នាំ បន្ទាប់មកគឺចន្លោះពីអាយុ ៤៥ ឆ្នាំ ឬច្រើនជាងនេះ (២២.៤%) និងអាយុ ២៤ ឆ្នាំ ឬក្មេងជាងនេះ (១៣.១%)។

*រូប 4.15. ភាគរយគ្រូបង្រៀនថ្នាក់ទី៥ តាមក្រុមអាយុគ្រូបង្រៀន*



### 4.3.3. គុណវុឌ្ឍិរបស់គ្រូបង្រៀន

សិស្សថ្នាក់ទី៥ ភាគច្រើននៅកម្ពុជា បង្រៀនដោយគ្រូបង្រៀនដែលមានសញ្ញាបត្របរិញ្ញាបត្រ (៤១.៤%) ឬមធ្យមសិក្សាទុតិយភូមិ (៤០.៦%) (សូមមើលរូប 4.16)។ ភាគរយសិស្សតិចតួចបង្រៀនដោយគ្រូដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រោយមធ្យមសិក្សា (៩.០%) ខណៈពេលដែលមានគ្រូតិចតួចណាស់ដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (៣.៦%), មធ្យមសិក្សាទុតិយភូមិ ឬទាបជាងនេះ (៤.៧%), ឬ បរិញ្ញាបត្ររង (០.៧%)។

*រូប 4.16. ភាគរយគ្រូបង្រៀនថ្នាក់ទី៥ តាមកម្រិតគុណវុឌ្ឍិរបស់គ្រូបង្រៀននៅឆ្នាំ២០២៤*




រូប 4.17 បង្ហាញពីលទ្ធផលរបស់សិស្សលើអំណាន និងគណិតវិទ្យា តាមកម្រិតអប់រំរបស់គ្រូ។ លទ្ធផលបង្ហាញថា សិស្សដែលបង្រៀនដោយគ្រូដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬខ្ពស់ជាងនេះ រៀនពូកែជាងសិស្សដែលបង្រៀនដោយគ្រូដែលមានការអប់រំមធ្យមសិក្សាទុតិយភូមិ ឬទាបជាងនេះ។

*រូប 4.17. លទ្ធផលអំណាន និងគណិតវិទ្យាតាមកម្រិតគុណវុឌ្ឍិរបស់គ្រូបង្រៀននៅឆ្នាំ២០២៤*




### 4.3.4. ការចូលរួមការបណ្តុះបណ្តាល

គ្រូបង្រៀនបានលើកឡើងអំពីប្រធានបទដែលពួកគាត់បានរៀនទាំងនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូ និងវគ្គវិក្រឹតការ រួមមាន ការគ្រប់គ្រងថ្នាក់រៀន (៩០.២%), វិធីសាស្ត្របង្រៀន/គរុកោសល្យ (៨៨.៧%), សំណេរ (៨៦.៩%), អំណាន (៨៦.៨%), គណិតវិទ្យា (៨៥.៧%) និងវង្វាយតម្លៃការសិក្សារបស់សិស្ស (៨៥.៦%)។ ទោះជាយ៉ាងណាក៏ដោយ គ្រូបង្រៀន ៥៧.៤% បានលើកឡើងថាមិនទទួលបានការបណ្តុះបណ្តាលលើផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT), ការអប់រំបរិយាបន្ន (៥២.៩%) និងការបង្រៀនតាមសមត្ថភាពសិស្ស (៣០.០%)។

*រូប 4.18. ភាគរយនៃការចូលរៀនរបស់គ្រូបង្រៀនថ្នាក់ទី៥ តាមប្រធានបទនីមួយៗនៅឆ្នាំ២០២៤*




## 4.3.5. ការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន

ដូចដែលបានបង្ហាញក្នុងរូប 4.19 សិស្សជាង ៩៩% រៀននៅសាលារៀនដែលគ្រូថ្នាក់ទី៥ ត្រូវបានវាយតម្លៃផ្អែកលើការសង្កេតដោយនាយកសាលា ឬប្រធានក្រុមបច្ចេកទេស។ សិស្ស ៩៥% រៀននៅសាលារៀនដែលគ្រូត្រូវបានវាយតម្លៃដោយផ្អែកលើលទ្ធផលសិស្សថ្នាក់ទី៥, ការសង្កេតថ្នាក់និទស្សន៍ (៧៦.៤%) និងការសង្កេតពីក្រុមអធិការកិច្ចមន្ទីរ ឬពីក្រសួងអប់រំ (៥០.៣%)។

*រូប 4.19. ភាគរយសិស្សតាមវិធីសាស្ត្រដែលប្រើនៅក្នុងសាលារៀនដើម្បីវាយតម្លៃគ្រូបង្រៀននៅឆ្នាំ២០២៤*



### 4.3.6. ទិដ្ឋភាពសំខាន់ៗនៃសកម្មភាពអំណាន

វាជាការសំខាន់ក្នុងការដឹងពីវិសាលភាពដែលគ្រូបង្រៀនផ្តោតលើទិដ្ឋភាពសំខាន់ៗនៃអំណាននៅពេលបង្រៀនសិស្សថ្នាក់ទី៥។ នៅក្នុងរង្វាយតម្លៃ SEA-PLM 2024 គ្រូបង្រៀនត្រូវបានសួរសំណួរជាបន្តបន្ទាប់អំពីសកម្មភាពបង្រៀនរបស់ពួកគាត់ (សូមមើលរូប 4.20)។ សិស្សបានលើកឡើងថា គ្រូបង្រៀនរបស់ពួកគេបានផ្តោតមធ្យម ឬផ្តោតខ្លាំងលើសកម្មភាពខាងក្រោម៖ ៩៨.១% ផ្តោតលើការកំណត់សួរនិងពាក្យ, ៩៨.0% លើអំណានស្ទាត់, និង ៩៧.១% លើការអានឮៗ។ ទោះជាយ៉ាងណាក៏ដោយ មានតែសិស្ស ៨២.៣% ប៉ុណ្ណោះដែលបានលើកឡើងថា គ្រូបង្រៀនរបស់ពួកគេបានផ្តោតលើវិធីអានត្រួសៗ។

*រូប 4.20. ភាគរយនៃគ្រូបង្រៀនថ្នាក់ទី៥ ដែលបានផ្តោតមធ្យម ឬផ្តោតខ្លាំងលើសកម្មភាពអំណាននៅឆ្នាំ២០២៤*




## 4.4. កត្តាថ្នាក់រៀន

ផ្នែកនេះផ្តល់នូវទិដ្ឋភាពទូទៅនៃកត្តាថ្នាក់រៀន រួមមានបរិយាកាសថ្នាក់រៀន សកម្មភាពអំណាន និងសកម្មភាពគណិតវិទ្យានៅក្នុងថ្នាក់រៀន។

### 4.4.1. បរិយាកាសថ្នាក់រៀន

សិស្សប្រហែល ៧០% បានរាយការណ៍ថា គ្រូបង្រៀនរបស់ពួកគេពេលខ្លះ ឬញឹកញាប់ មានការលំបាកក្នុងការធ្វើឱ្យសិស្សស្ងៀមស្ងាត់ ដែលបង្ហាញថាគ្រូបង្រៀនមានបញ្ហាការគ្រប់គ្រងថ្នាក់រៀន។ លើសពីនេះ សិស្ស ៤៦.៣% បានកត់សម្គាល់ថា គ្រូបង្រៀនរបស់ពួកគេមកបង្រៀនយឺត ហើយសិស្ស ៤២.៧% បានលើកឡើងថាគ្រូបង្រៀនអវត្តមាន។

*រូប 4.21. ភាគរយសិស្សថ្នាក់ទី៥ ដែលបានលើកឡើងពីបញ្ហាកើតមានក្នុងថ្នាក់រៀន ម្តងម្កាល ឬ ញឹកញាប់នៅឆ្នាំ២០២៤*




## 4.4.2. សកម្មភាពអំណានក្នុងថ្នាក់រៀន

រូប 4.22 បង្ហាញពីភាគរយគ្រូបង្រៀនថ្នាក់ទី៥ ដែលអនុញ្ញាតឱ្យសិស្សអានស្ងាត់ (៨៣.០%), អានឮខ្លាំងៗ (៧៧.៩%), និងអានតាមគ្រូ (៦៦.៨%) ជារៀងរាល់ថ្ងៃ ឬស្ទើររៀងរាល់ថ្ងៃ។ លើសពីនេះ គ្រូបង្រៀន ៦៤.៩% បានបង្ហាញថា ពួកគាត់បានអនុញ្ញាតឱ្យសិស្សខ្ចីសៀវភៅទៅអាននៅផ្ទះ ចំណែកឯគ្រូបង្រៀន ៤៦.៧% បាននិយាយថាសិស្សអានសៀវភៅដែលចូលចិត្ត ជាញឹកញាប់។

*រូប 4.22. ភាគរយគ្រូបង្រៀនថ្នាក់ទី៥ ដែលអនុញ្ញាតឱ្យសិស្សធ្វើសកម្មភាពអំណានដូចខាងក្រោម ក្នុងថ្នាក់រៀននៅឆ្នាំ២០២៤*



### 4.4.3. សកម្មភាពអានយល់ន័យក្នុងថ្នាក់រៀន

គ្រូបង្រៀនថ្នាក់ទី៥ ភាគច្រើនលើកឡើងថា សិស្សរបស់ពួកគាត់តែងតែចូលរួមក្នុងសកម្មភាពអានយល់ន័យនៅក្នុងថ្នាក់។ គ្រូបង្រៀនថ្នាក់ទី៥ បានលើកឡើងថា សិស្សរបស់ពួកគាត់តែងតែពន្យល់ន័យនៃពាក្យពិបាក (៨៣.៤%), កំណត់គំនិតសំខាន់ៗនៅក្នុងអត្ថបទ (៦៩.៣%), និងវាយតម្លៃគំនិតក្នុងអត្ថបទ (៦៥.២%) ប្រចាំថ្ងៃ ឬស្ទើររៀងរាល់ថ្ងៃ។ លើសពីនេះ សិស្សជាងពាក់កណ្ដាលបានអនុវត្តការទាញយកព័ត៌មានពីអត្ថបទ (៥៤.៣%), វាយតម្លៃអត្ថរូប និងអត្ថន័យរបស់អត្ថបទ (៥៤.៣%) និងសង្ខេបអ្វីដែលពួកគេបានអាន (៤៦.៧%)។ ជាចុងក្រោយ គ្រូបង្រៀន ៣៨.៤% បានលើកឡើងថា សិស្សរបស់ពួកគេវិភាគសំណង់ប្រយោគ និងទម្រង់នៃអត្ថបទ ហើយគ្រូបង្រៀន ៧០.៧ % បានលើកឡើងថា សិស្សឆ្លុះបញ្ចាំងពីអត្ថបទទៅនឹងបទពិសោធផ្ទាល់ខ្លួនរបស់សិស្ស។

*រូប 4.23. ភាគរយគ្រូបង្រៀនថ្នាក់ទី៥ ដែលលើកឡើងថាសិស្សរបស់ពួកគាត់បានធ្វើសកម្មភាពអានយល់ន័យនៅឆ្នាំ២០២៤*




### 4.4.4. សកម្មភាពគណិតវិទ្យាក្នុងថ្នាក់រៀន

គ្រូបង្រៀន ៩៦.៨% បានលើកឡើងថាសិស្សរបស់ពួកគាត់ស្ដាប់គ្រូបង្រៀនពន្យល់អំពីខ្លឹមសារគណិតវិទ្យាជាប្រចាំ ឬស្ទើររៀងរាល់ថ្ងៃ ខណៈពេលដែលគ្រូបង្រៀន ៨៤.៣% និយាយថាសិស្សទន្ទេញរូបមន្ត វិធីដោះស្រាយ និងភាពពិតជាក់ស្ដែង ជាញឹកញាប់។ លើសពីនេះ គ្រូបង្រៀន ៨៣.០% បានលើកឡើងថា សិស្សរបស់ពួកគាត់ដោះស្រាយលំហាត់គណិតវិទ្យានៅលើក្រដាសជាប្រចាំ ហើយ ៧៧.៩% បានបកស្រាយចម្លើយរបស់លំហាត់គណិតវិទ្យាពួកគេ។ ទោះជាយ៉ាងណាក៏ដោយ គ្រូបង្រៀន ៧៥.៩% បានលើកឡើងថាពួកគេផ្សារភ្ជាប់គណិតវិទ្យាទៅនឹងជីវិតប្រចាំថ្ងៃ, ៧៥.០% បានឱ្យសិស្សរបស់ពួកគាត់ដោះស្រាយលំហាត់

គណិតវិទ្យារួមគ្នាលើក្ដារខៀន, ៥៤.៥% ឱ្យសិស្សចូលរួមក្នុងការដោះស្រាយលំហាត់ជាក្រុមតូចៗ, ២២.៩% បានឱ្យសិស្សចូលរួមក្នុងសកម្មភាពបន្ថែមដែលមានភាពលំបាកខ្លាំង។ សិស្ស ២.៦% សិក្សាគណិតវិទ្យាតាមកុំព្យូទ័រ។

*រូប 4.24. ភាគរយគ្រូបង្រៀនថ្នាក់ទី៥ ដែលលើកឡើងថាសិស្សរបស់ពួកគាត់បានធ្វើសកម្មភាពគណិតវិទ្យាក្នុងថ្នាក់រៀននៅឆ្នាំ២០២៤*




## 4.5. កត្តាសាលារៀន

ផ្នែកនេះរៀបរាប់ពីកត្តាសាលារៀន ដូចជា ភេទនាយកសាលា បទពិសោធជានាយក ទំហំសាលារៀន សមាមាត្រសិស្ស-គ្រូ បណ្ណាល័យ នីតិវិធីត្រួតពិនិត្យ បញ្ហាសិស្សដែលកើតមាន បញ្ហាដែលរារាំងសមត្ថភាពសាលារៀន និងការឆ្លើយតបគោលនយោបាយរបស់សាលារៀនចំពោះជំងឺកូវីដ-១៩។

### 4.5.1. ភេទនាយកសាលា

ដោយផ្អែកលើរង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ នាយកសាលា ជាបុរសមានចំនួនច្រើនជាងស្ត្រីៈ បុរស ៨៥% ធៀបនឹងស្ត្រី ១៥%។ ការរកឃើញនេះឆ្លុះបញ្ចាំងពីគម្លាតយេនឌ័រក្នុងការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំនៅកម្រិតសាលារៀននៅកម្ពុជា។

### 4.5.2. បទពិសោធជានាយកសាលា

លទ្ធផលបង្ហាញថាសិស្សភាគច្រើន (៣៦.៦%) រៀននៅក្នុងសាលារៀនដែលដឹកនាំដោយនាយកសាលាដែលមានបទពិសោធពី ៦-១០ ឆ្នាំ, សិស្ស ៣០.៤% ដែលមាននាយកសាលាមានបទពិសោធពី ១១-២០ ឆ្នាំ។ ទន្ទឹមនឹងនេះ សិស្ស ១៧.៥% ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកសាលាដែលមានបទពិសោធពី ៣-៥ ឆ្នាំ និង សិស្ស ៨.៩% មាននាយកសាលាដែលមានបទពិសោធ ២ ឆ្នាំ ឬតិចជាងនេះ។ មានតែសិស្ស ៦.៦% ប៉ុណ្ណោះដែលមាននាយកសាលាដែលមានបទពិសោធជានាយកសាលាច្រើនឆ្នាំ (ច្រើនជាង ២១ ឆ្នាំ)។

*រូប 4.25. ភាគរយសិស្សតាមបទពិសោធជានាយករបស់នាយកសាលានៅឆ្នាំ២០២៤*




### 4.5.3. ទំហំសាលារៀន

ជាមធ្យមចំនួនសិស្សនៅក្នុងសាលាបឋមសិក្សាកម្ពុជានៅឆ្នាំ២០២៤ មានសិស្ស ៦៥២នាក់ ខណៈដែលនៅឆ្នាំ២០១៩ មានសិស្ស ៦៩០នាក់ ក្នុងមួយសាលា។ នាយកសាលាបានលើកឡើងថា សិស្ស ១៨.៤% កំពុងសិក្សានៅសាលារៀនដែលមានសិស្សតិចជាង ២០០នាក់ (សាលាទំហំតូច)។ សិស្ស ៣០.២% កំពុងរៀននៅសាលារៀនដែលមានសិស្សចាប់ពី ២០០នាក់ ទៅ ៤៩៩នាក់ (សាលាទំហំមធ្យម)។ សិស្សកម្ពុជាថ្នាក់ទី៥ ៣៥.៣% កំពុងរៀននៅសាលារៀនដែលមានសិស្សចាប់ពី ៥០០នាក់ ទៅ ៩៩៩នាក់ និង សិស្ស ១៦.២% រៀននៅសាលារៀនដែលមានសិស្សចាប់ពី ១០០០នាក់ ឡើងទៅ (សាលាទំហំធំ)។

*រូប 4.26. ទំហំសាលារៀនជាមធ្យមនៅឆ្នាំ២០២៤*




## 4.5.4. ផលធៀបសិស្ស-គ្រូ

សមាមាត្រសិស្ស-គ្រូជាមធ្យមបានថយចុះពី ៤៣នាក់ ក្នុងឆ្នាំ២០១៩ មកត្រឹម ៣៦នាក់ ក្នុងឆ្នាំ២០២៤។ លើសពីនេះទៅទៀត នៅឆ្នាំ២០២៤ សមាមាត្រសិស្ស-គ្រូ ក្នុងសាលារៀននៅក្នុងទីប្រជុំជន និងជនបទគឺប្រហាក់ប្រហែលគ្នា (សូមមើលរូប 4.27)។

*រូប 4.27. ផលធៀបសិស្ស-គ្រូ ជាមធ្យមតាមទីតាំងសាលារៀននៅឆ្នាំ២០១៩ និង២០២៤*




## 4.5.5. សៀវភៅសិក្សាគោល

នាយកសាលារៀនដែលបានចូលរួមក្នុងវង្វាយតម្លៃ SEA-PLM ត្រូវបានសួរនាំអំពីស្ថានភាពសៀវភៅសិក្សាគោលភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី៥។ ដូចបង្ហាញក្នុងរូប 4.28 សិស្ស ៩៦.៤% រៀននៅសាលារៀន ដែលមានសៀវភៅសិក្សាគោលភាសាខ្មែរមួយក្បាលសម្រាប់សិស្សម្នាក់ៗ ខណៈដែលសិស្ស ១.៥% ប្រើប្រាស់សៀវភៅសិក្សាគោលភាសាខ្មែររួមគ្នា និងសិស្ស ២.១% មិនមានសៀវភៅសិក្សាគោលភាសាខ្មែរទេ។ ស្រដៀងគ្នានេះដែរ សិស្ស ៩៣.៦% រៀននៅសាលាដែលមានសៀវភៅសិក្សាគោលគណិតវិទ្យាមួយក្បាលសម្រាប់សិស្សម្នាក់ៗ ហើយ សិស្ស ៦.៤% បានលើកឡើងថាមិនមានសៀវភៅសិក្សាគោលគណិតវិទ្យាទេ។

*រូប 4.28. ភាគរយសិស្សតាមស្ថានភាពសៀវភៅសិក្សាគោលភាសាខ្មែរ និងគណិតវិទ្យានៅឆ្នាំ២០២៤*




### 4.5.6. បណ្ណាល័យ

ដូចដែលបានបង្ហាញក្នុងរូប 4.29 សិស្ស ៧៧.៥% រៀននៅសាលាដែលមានបណ្ណាល័យ ចំណែកឯសិស្ស ២២.៥% រៀននៅសាលារៀនដែលគ្មានបណ្ណាល័យ។

*រូប 4.29. ភាគរយសិស្សតាមស្ថានភាពសាលារៀនដែលមានឬគ្មានបណ្ណាល័យនៅឆ្នាំ២០២៤*




ប្រសិនបើនាយកសាលារៀនបានលើកឡើងថាមានបណ្ណាល័យ ពួកគាត់ត្រូវបានស្នើសុំឱ្យរាយការណ៍អំពីធនធាន និងសេវាកម្ម នៅក្នុងបណ្ណាល័យ ដែលគាំទ្រដល់ការសិក្សារបស់សិស្ស។ ដូចបង្ហាញក្នុងរូប 4.30 សិស្ស ៩៥.៧% រៀននៅសាលារៀនដែលបណ្ណាល័យមានសៀវភៅរឿងប្រឌិត ក្រៅពីនេះមានការឱ្យសៀវភៅសិស្សខ្ចី (៩២.៨%) និងសៀវភៅគ្រូ (៩១.៦%)។ លើសពីនេះ សិស្ស ៨៨.១% រៀននៅសាលារៀនដែលបណ្ណាល័យមានបន្ទប់អាន និង ៨៣.៦% មានបណ្ណារក្ស ដែលបង្ហាញថាបណ្ណាល័យសាលាជាច្រើនត្រូវបានរៀបចំយ៉ាងល្អ និងគ្រប់គ្រងយ៉ាងសកម្ម។ ទោះជាយ៉ាងណាក៏ដោយ មានតែសិស្ស ១៥.២% និង ១៤.៥% រៀននៅសាលារៀនដែលបណ្ណាល័យមានកុំព្យូទ័រ និងកាសែតរៀងគ្នា។

រូប 4.30. ធនធាន និងសេវាកម្មនៅបណ្ណាល័យនៅឆ្នាំ២០២៤




## 4.5.7. ការត្រួតពិនិត្យវត្តមានសិស្ស

នាយកសាលាត្រូវបានសួរនាំអំពីរបៀបត្រួតពិនិត្យវត្តមានសិស្ស។ ដូចបង្ហាញក្នុងរូប 4.31 សិស្ស ៩៦.៦% រៀននៅសាលារៀនដែលនាយកសាលាបានលើកឡើងថាវត្តមានត្រូវបានកត់ត្រាជារៀងរាល់ថ្ងៃ ដែលឆ្លុះបញ្ចាំងពីការប្រកាន់យ៉ាងខ្ជាប់ខ្ជួនចំពោះបទបញ្ជាផ្ទៃក្នុងសាលាទាក់ទងនឹងវត្តមានសិស្ស ។ ទន្ទឹមនឹងនេះ សិស្ស ៦៦.៥% រៀននៅសាលារៀនដែលនាយកសាលាបានបង្ហាញថាអវត្តមានរបស់សិស្សត្រូវបានផ្តល់ដំណឹងទៅសាលា តាមរយៈសិស្សខ្លួនឯង ឬឪពុកម្តាយរបស់ពួកគេ។ លើសពីនេះ សិស្ស ៦១.៦% និង ៤១.៦% រៀននៅសាលារៀនដែលនាយកសាលាបានបញ្ជាក់ថាវត្តមានត្រូវបានកត់ត្រាតាមម៉ោងរៀននីមួយៗ និងនាយកសាលាត្រួតពិនិត្យវត្តមានសិស្សដោយផ្ទាល់ រៀងគ្នា។

រូប 4.31. ភាគរយសិស្សតាមរបៀបត្រួតពិនិត្យវត្តមានសិស្សនៅឆ្នាំ២០២៤



### 4.5.8. ការត្រួតពិនិត្យសាលារៀន

នាយកសាលាដែលបានចូលរួមក្នុងវង្វាយតម្លៃ SEA-PLM ត្រូវបានសួរនាំអំពីភាពញឹកញាប់ដែលបុគ្គលិកអប់រំ ឬក្រុមការងារ បានចុះទៅសាលារៀនរបស់ពួកគាត់ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។ សិស្សប្រហែល ៤៥% រៀននៅសាលារៀនដែលនាយកសាលាបានលើកឡើងថា គ្រូឧទ្ទេសបានទៅទស្សនកិច្ចនៅសាលារៀនរបស់ពួកគាត់យ៉ាងហោចណាស់ម្តងក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។ សិស្ស ៦៨% រៀននៅសាលារៀនដែលក្រុមអធិការកិច្ចបានទៅទស្សនកិច្ចយ៉ាងតិចម្តង និង សិស្ស ៧៥% រៀននៅសាលារៀនដែលនាយកសាលាបានលើកឡើងថា ក្រុមអធិការ ឬក្រុមអ្នកត្រួតពិនិត្យបានទៅទស្សនកិច្ចសាលារៀនយ៉ាងហោចណាស់ម្តងក្នុងរយៈពេលពីរឆ្នាំចុងក្រោយ (សូមមើលរូប 4.32)។

*រូប 4.32. ភាគរយសិស្សរៀននៅសាលារៀនដែលបានទទួលការចុះត្រួតពិនិត្យក្នុងរយៈពេលពីរឆ្នាំចុងក្រោយ*




### 4.5.9. បញ្ហាសិស្សកើតមាននៅសាលារៀន

ដើម្បីស្វែងយល់បន្ថែមអំពីបញ្ហាដែលកើតឡើងនៅសាលារៀនក្នុងចំណោមសិស្ស នាយកសាលាត្រូវបានសួរនាំអំពីបញ្ហាដែលកើតមានញឹកញាប់។ ដូចបង្ហាញក្នុងរូប 4.33 សិស្សរៀននៅសាលារៀនដែលមានបញ្ហាសិស្សមករៀនយឺត(៥៣.៧%), ការរំខានគ្នាក្នុងថ្នាក់រៀន (៤៦.១%), ការលួចមើលឬលួចចម្លងពេលប្រឡង (៣៩.៨%) និងគេចសាលា (១៧.៨%) បានកើតឡើងយ៉ាងហោចណាស់ម្តងក្នុងមួយខែ។

*រូប 4.33. ភាគរយសិស្សតាមប្រភេទបញ្ហាដែលកើតឡើងក្នុងចំណោមសិស្សនៅសាលារៀនយ៉ាងហោចណាស់ម្តងក្នុងមួយខែនៅឆ្នាំ២០២៤*




## 4.5.10. បញ្ហាដែលរារាំងសមត្ថភាពសាលារៀន

ដូចដែលបានបង្ហាញក្នុងរូប 4.34 នាយកសាលាបានកំណត់កត្តាមួយចំនួនដែលរារាំងសមត្ថភាពសាលារៀនរបស់ពួកគាត់ក្នុងការផ្តល់ការរៀនសូត្រប្រកបដោយប្រសិទ្ធភាព។ សិស្ស ៧១.៦% រៀននៅសាលារៀនដែលមានបញ្ហាខ្វះបរិក្ខារឱ៍ជីថល, ខ្វះបន្ទប់រៀន (៤៤.២%) និងខ្វះគ្រូបង្រៀនដែលមានសមត្ថភាព (៣៥.២%)។ លើសពីនេះ សិស្ស ៣១.៦% រៀននៅសាលារៀនដែលខ្វះបង្គន់អនាម័យ និង និងខ្វះសម្ភារបង្រៀននិងរៀន (២៣.២%)។

*រូប 4.34. ភាពញឹកញាប់នៃបញ្ហាដែលលើកឡើងដោយនាយកសាលាដែលបានរាំងដល់ដំណើររៀនសូត្រនៅឆ្នាំ២០២៤*



### 4.5.11. បញ្ហាប្រឈមរបស់សាលារៀនក្នុងអំឡុងពេលនៃជំងឺរាតត្បាតកូវីដ-១៩

ដូចដែលបានបង្ហាញក្នុងរូប 4.35 សិស្សប្រហែល ៧០% រៀននៅសាលារៀនដែលនាយកសាលាបានលើកឡើងពីបញ្ហាគ្រូបង្រៀនខ្វះចំណេះដឹង ICT, កង្វះហេដ្ឋារចនាសម្ព័ន្ធឌីជីថល, សិស្សដែលមានជំនាញ ICT មិនគ្រប់គ្រាន់ និងការចូលប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលមានកម្រិតសម្រាប់ការរៀនសូត្រតាមអ៊ីនធឺណិត ដែលប៉ះពាល់កម្រិតមធ្យម ឬកម្រិតខ្លាំងដល់សាលារៀនក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩។ លើសពីនេះ សិស្សប្រហែល ៦០% រៀននៅសាលារៀនដែលនាយកសាលាបានលើកឡើងថា លទ្ធផលសិក្សារបស់សិស្សលើអំណាន និងគណិតវិទ្យា ត្រូវបានជះឥទ្ធិពលជាអវិជ្ជមានដោយជំងឺរាតត្បាតនេះ។

*រូប 4.35. ភាគរយសិស្សដែលរៀននៅសាលារៀនដែលនាយកសាលាបានលើកឡើងថាបញ្ហាដូចខាងក្រោមបានប៉ះពាល់ដល់សាលារៀនកម្រិតមធ្យម ឬកម្រិតខ្លាំងក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩ នៅឆ្នាំ២០២៤*




### 4.5.12. សកម្មភាពសាលារៀនឆ្លើយតបចំពោះជំងឺរាតត្បាតកូវីដ-១៩

ដូចដែលបានបង្ហាញក្នុងរូប 4.36 សិស្ស ៧៩.៦% និង ៧៥.៥% រៀននៅសាលារៀន ដែលនាយកសាលាបានលើកឡើងថា សាលារៀនបានផ្តល់ការបំប៉នលើផ្នែកអំណាន និងគណិតវិទ្យា នៅពេលចូលរៀនវិញបន្ទាប់ពីជំងឺរាតត្បាតកូវីដ-១៩ សម្រាប់សិស្សទាំងអស់ រៀងគ្នា។ លើសពីនេះ សិស្សប្រហែល

៧០% រៀននៅសាលារៀនដែលណែនាំគ្រួសារអំពីការគាំទ្រដល់ការរៀនសូត្ររបស់កុមារ និងចែកចាយសម្ភារសិក្សាជាក្រដាសសម្រាប់ប្រើប្រាស់។ ទោះជាយ៉ាងណាក៏ដោយ មានសិស្សតិចជាង ៣៧% រៀននៅសាលារៀនដែលមានការបង្រៀនពីចម្ងាយតាមរយៈអ៊ីនធឺណិត និងមានអ្នកប្រឹក្សា និងសេវាសុខភាពផ្លូវចិត្ត។

*រូប 4.36. ភាគរយសិស្សរៀននៅសាលារៀនដែលនាយកសាលាបានលើកឡើងថាសាលារៀនបានផ្តល់សកម្មភាពដូចខាងក្រោមដើម្បីឆ្លើយតបទៅនឹងជំងឺរាតត្បាតកូវីដ-១៩ នៅឆ្នាំ២០២៤*




## 4.6. កត្តាសហគមន៍

ផ្នែកនេះផ្តល់នូវទិដ្ឋភាពទូទៅនៃលក្ខណៈសហគមន៍ រួមទាំងការចូលរួមរបស់ឪពុកម្តាយចំពោះការសិក្សា ការជួយពីឪពុកម្តាយក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ និងការចូលរួមរបស់សហគមន៍។

### 4.6.1. ការចូលរួមរបស់មាតាបិតាចំពោះការសិក្សា

នៅក្នុងវង្វាយតម្លៃ SEA-PLM សិស្សត្រូវបានសួរអំពីការចូលរួមរបស់មាតាបិតារបស់ពួកគេនៅក្នុងសកម្មភាពទាក់ទងនឹងសាលារៀននៅផ្ទះ។ ដូចដែលបានបង្ហាញក្នុងរូប 4.37 សិស្ស ៦០.៥% បាននិយាយថាមាតាបិតារបស់ពួកគេបានលើកទឹកចិត្តឱ្យខិតខំរៀនសូត្រ ចំណែកឯសិស្ស ៤៤.២% បាន

និយាយថាមាតាបិតារបស់ពួកគេតែងតែតាមដានការធ្វើកិច្ចការផ្ទះជារៀងរាល់ថ្ងៃ។ ស្រដៀងគ្នានេះដែរ សិស្ស ៤២.៣% បានរាយការណ៍ថាមាតាបិតារបស់ពួកគេបានសួរនាំអំពីការរៀនសូត្រ។ ប្រហែលមួយភាគបី (៣៤.០%) បាននិយាយថាពួកគេសួរនាំមាតាបិតាអំពីកិច្ចការសាលារៀន។ ទោះជាយ៉ាងណាក៏ដោយ មានតែសិស្ស ២៤.៦% ប៉ុណ្ណោះដែលនិយាយថាមាតាបិតារបស់ពួកគេជួយធ្វើលំហាត់នៅផ្ទះ។

*រូប 4.37. ភាគរយសិស្សតាមប្រភេទសកម្មភាពនៅផ្ទះនៅឆ្នាំ២០២៤*




សិស្សដែលមានមាតាបិតាយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូន ទទួលបានពិន្ទុខ្ពស់ជាងសិស្សដែលមានមាតាបិតាមិនសូវយកចិត្តទុកដាក់ លើអំណាន ១១ពិន្ទុ និងគណិតវិទ្យា ១០ពិន្ទុ (រូប 4.38)។

*រូប 4.38. លទ្ធផលអំណាន និងគណិតវិទ្យាតាមកម្រិតនៃការចូលរួមរបស់មាតាបិតាក្នុងការសិក្សារបស់កូន នៅឆ្នាំ២០២៤*




## 4.6.2. ការចូលរួមគាំទ្ររបស់មាតាបិតាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩

រូប 4.39 បង្ហាញពីភាគរយសិស្សថ្នាក់ទី៥ ដែលបានលើកឡើងថាមាតាបិតារបស់ពួកគេបានជួយក្នុងទម្រង់ផ្សេងៗ ក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩។ លទ្ធផលបង្ហាញថា ខណៈដែលមាតាបិតាមួយចំនួនបានគាំទ្រយ៉ាងសកម្មដល់ការសិក្សារបស់កូនៗពួកគាត់ ប៉ុន្តែនៅមានសិស្សជាច្រើនបានទទួលការជួយនៅមានកម្រិត ជាពិសេសនៅក្នុងការសិក្សាតាមឌីជីថល។ សិស្សជាងពាក់កណ្តាលបានលើកឡើងថាមាតាបិតារបស់ពួកគេបានជួយពួកគេឱ្យប្រើប្រាស់សម្ភារសិក្សា(៦២.៣%) ឬពិនិត្យមើលថាតើពួកគេបានធ្វើកិច្ចការសាលាឬទេ (៦០.២%) គ្រប់ពេល ដែលនេះបង្ហាញពីតួនាទីរបស់មាតាបិតាក្នុងការត្រួតពិនិត្យនៅផ្ទះយ៉ាងម៉ត់ចត់។ សិស្សប្រហែល ៥៥% បានលើកឡើងថា ពួកគេបានទទួលការជួយជាប្រចាំលើការអាន និងការសរសេរ ហើយបានសួរនាំអំពីការរៀនសូត្ររបស់ពួកគេ។ លើសពីនេះ សិស្ស ៤៦.០% បានលើកឡើងថាមាតាបិតារបស់ពួកគេបានជួយលើការរៀនគណិតវិទ្យា ហើយសិស្សប្រហែល ៤៥.២% បាននិយាយថា មាតាបិតារបស់ពួកគេតែងតែដាក់បញ្ជូនកិច្ចការផ្ទះ ឬកិច្ចការទៅគ្រូ។ ទោះជាយ៉ាងណាក៏ដោយមានតែសិស្ស ១៧.៩% ប៉ុណ្ណោះដែលនិយាយថា មាតាបិតារបស់ពួកគេតែងតែជួយពួកគេប្រើប្រាស់ឧបករណ៍ ICT និងជួយពន្យល់ប្រធានបទថ្មីៗ (៣៣.៧%)។

*រូប 4.39. ភាគរយសិស្សតាមប្រភេទនៃការជួយរបស់មាតាបិតាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ នៅឆ្នាំ២០២៤*




### 4.6.3. ការចូលរួមរបស់សហគមន៍

រូប 4.40 បង្ហាញពីការចូលរួមរបស់សហគមន៍ក្នុងសកម្មភាពផ្សេងៗរបស់សាលារៀន។ សិស្ស ៥០.៩% រៀននៅសាលារៀនដែលនាយកសាលាបានលើកឡើងថាសហគមន៍បានចូលរួមក្នុងការថែទាំអគារសិក្សា (៥០.៩%), ការរៃអង្គាសថវិកា (៣៨.៤%) និងការជួយក្នុងថ្នាក់រៀន (៣៥.៣%)។ ម្យ៉ាងវិញទៀត សិស្ស ១២.៨% រៀននៅសាលារៀនដែលនាយកសាលាបានលើកឡើងថាសហគមន៍បានចូលរួមក្នុងការរៀបចំសកម្មភាពកម្មវិធីសិក្សាបន្ថែម និងការគាំទ្រការបំប៉នសិស្សរៀនយឺត (១០.៧%)។

*រូប 4.40. សហគមន៍បានចូលរួមសកម្មភាពខាងក្រោមនៅឆ្នាំ២០២៤*



# ជំពូកទី៥ ទិធានការលើកកម្ពស់មូលដ្ឋានគ្រឹះនៃការសិក្សា

អាស្រ័យដោយមានបទពិសោធរឹងមាំលើកំណែទម្រង់ ជាពិសេសក្នុងការផលិតសម្ភារបង្រៀន និងរៀននៅកម្រិតបឋមសិក្សា ការអប់រំវិក្រឹតការ យន្តការណែនាំនៅកម្រិតកម្រង និងការប្រើប្រាស់បច្ចេកវិទ្យា ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តគាំទ្រយន្តការលើកកម្ពស់គុណភាពអប់រំ ជានានិរន្តរភាព និងពង្រីកវិសាលភាពនៃកំណែទម្រង់។ កិច្ចខិតខំប្រឹងប្រែងរួមគ្នាទាំងនេះបានគាំទ្រកម្មវិធីកំណែទម្រង់ដែលកំពុងមានស្រាប់រួមមាន៖

## 5.1. សេចក្តីសង្ខេបអនុសាសន៍ដកស្រង់ពីរបាយការណ៍ថ្នាក់តំបន់

នៅក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ថ្នាក់តំបន់ជាផ្លូវការ (នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥) អនុសាសន៍ចំនួន១០ ត្រូវបានលើកឡើង រួមមាន៖

1. បង្កើនការវិនិយោគលើមូលដ្ឋានគ្រឹះនៃការសិក្សា ដោយផ្តល់អាទិភាពដល់សិស្ស និងសាលារៀនដែលងាយរងគ្រោះបំផុត។
2. បន្តវិនិយោគលើការកសាងប្រព័ន្ធអប់រំដែលមានភាពធន់ ដើម្បីជួយសិស្ស និងសាលារៀន ឱ្យអាចប្រឈមមុខនឹងផលប៉ះពាល់ផ្សេងៗ។
3. រៀបចំយុទ្ធសាស្ត្រថ្នាក់ពន្លឿន និងផ្តល់ការគាំទ្រដល់សិស្សរៀនយឺត ដើម្បីលើកកម្ពស់លទ្ធផលសិក្សាឱ្យប្រសើរឡើង។
4. លើកកម្ពស់ការអប់រំបរិយាបន្ន និងឆ្លើយតបទៅនឹងយេនឌ័រ ដើម្បីធានាថាសិស្សទាំងអស់ទទួលបានការសិក្សាពេញលេញ។
5. ដោះស្រាយវិសមភាពអប់រំ ដែលកើតមានដោយសារស្ថានភាពសេដ្ឋកិច្ច-សង្គមខុសគ្នា និងការឈ្វេងយល់ពីកត្តាផ្សេងៗទៀតដែលជះឥទ្ធិពលលើការសិក្សារបស់សិស្ស។
6. ធានាសមធម៌ក្នុងការផ្តល់កិច្ចអន្តរាគមន៍ផ្នែកការអប់រំកុមារតូច ការគាំទ្រគ្រូបង្រៀន និងការរៀបចំបរិយាកាសរៀនសូត្រ ជាដើម។
7. បន្ស៊ីគោលនយោបាយស្តីពីការប្រើប្រាស់ភាសាក្នុងការសិក្សា ឱ្យត្រូវគ្នានឹងភាសាដែលសិស្សប្រើប្រាស់ប្រចាំថ្ងៃនៅផ្ទះ។
8. ពង្រឹងគុណវុឌ្ឍិគ្រូបង្រៀនដោយផ្តោតលើ វិធីសាស្ត្របង្រៀនផ្អែកតាមសមត្ថភាពសិស្ស ការបង្រៀនប្រកបដោយបរិយាបន្ន និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (ICT)។
9. បង្កើនសមភាព និងប្រសិទ្ធភាពនៃការវិនិយោគលើវិស័យអប់រំ ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាពតាមប្រទេសនីមួយៗ។
10. ប្រើប្រាស់ទិន្នន័យដើម្បីរៀបចំគោលនយោបាយ និងការពង្រឹងលើការត្រួតពិនិត្យវឌ្ឍនភាពនៃប្រព័ន្ធអប់រំ ដើម្បីធានាប្រសិទ្ធភាពនៃការវិនិយោគ។

## 5.2. វិធានការចម្បងៗសម្រាប់ឆ្លើយតបនឹងលទ្ធផលវាយតម្លៃ SEA-PLM ឆ្នាំ ២០២៤ របស់កម្ពុជា

### 5.2.1. កែលម្អការត្រៀមខ្លួនសិក្សារបស់កុមារ តាមរយៈការអប់រំកុមារតូច

- ពង្រឹង និងពង្រីកការអប់រំកុមារតូចនៅតាមសហគមន៍ សហគ្រាស និងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន
- បន្តផ្តល់ឱកាសដល់កុមារឱ្យបានបញ្ចប់ថ្នាក់មត្តេយ្យសិក្សា មុនពេលចូលរៀននៅកម្រិតបឋមសិក្សា
- ផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដល់គ្រូបង្រៀនកម្រិតមត្តេយ្យសិក្សា និងអ្នកជំនាញអប់រំកុមារស្តីអំពីជំនាញបង្រៀន និងថែទាំកុមារផ្អែកលើល្បែងសិក្សា។

### 5.2.2. កែលម្អការសិក្សាមូលដ្ឋានគ្រឹះ តាមរយៈអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង

- ពង្រីកការអនុវត្តកញ្ចប់សិក្សាថ្នាក់ដំបូងទូទាំងប្រទេស តាមរយៈការផ្តល់កញ្ចប់សម្ភារថ្នាក់ដំបូង (EGL) ដល់គ្រូបឋមសិក្សាទាំងអស់
- ពង្រឹងវិធីសាស្ត្របង្រៀនលើផ្នែកអំណាន និងគណិតវិទ្យា
- ពង្រឹងសកម្មភាពបណ្ណាល័យ និងលើកកម្ពស់ការអាននៅក្នុងបណ្ណាល័យ
- រៀបចំការប្រកួតអំណាននៅកម្រិតសាលារៀន
- ពង្រឹងការអនុវត្តកម្មវិធីសិក្សាតាមថ្នាលបឋម (PLP) សម្រាប់គ្រូបង្រៀន និងសិស្សក្នុងការបង្រៀន ការរៀន និងតេស្តវង្វាយតម្លៃ
- ពង្រីកការអនុវត្តកម្មវិធីបង្រៀនសម្របសមត្ថភាពសិស្សរៀនយឺត (Personalized Teaching to Overcome Marginalization [PTOM]) ដើម្បីធានាថាសិស្សរៀនត្រូវនឹងកម្រិតថ្នាក់ កាត់បន្ថយអត្រាត្រួតថ្នាក់ ការបោះបង់ការសិក្សា និងបង្កើនអត្រាបញ្ចប់កម្រិតបឋមសិក្សា។

### 5.2.3. កែលម្អការអភិបាលកិច្ចសាលារៀននៅកម្រិតបឋមសិក្សា

- អនុវត្តស្តង់ដាសាលារៀនគំរូដោយផ្តោតលើ ក) សាលារៀនមានគណនេយ្យភាពចំពោះសហគមន៍ និងការសម្រេចបានស្តង់ដាសាលារៀនគំរូ ខ) សាលារៀនមានស្វ័យភាពលើផែនការកែលម្អសាលារៀន និងផ្តល់ការកសាងសមត្ថភាពជាប្រចាំដល់សមាជិកនៃគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន គ) សិស្សត្រូវធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ដើម្បីកែលម្អការបង្រៀននិងការរៀន ដើម្បីជួយសិស្សខ្សោយ និងផ្តល់ព័ត៌មានចាំបាច់ដល់មាតាបិតាសិស្ស និងសហគមន៍ ឃ) គ្រូបង្រៀនប្រើប្រាស់លទ្ធផលនៃការវាយតម្លៃដើម្បីកែលម្អការបង្រៀន និងអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ ង) មាតាបិតាសិស្ស និងសហគមន៍ត្រូវចូលរួមនិងគាំទ្រដល់ការអភិវឌ្ឍសាលារៀន។
- ប្រសិទ្ធភាពនៃដំណើរការអភិបាលកិច្ចសាលារៀនអាស្រ័យលើការអនុវត្តវិធានការដូចខាងក្រោម៖

○ **ពង្រឹងការគ្រប់គ្រងសាលារៀន៖** រួមមានការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហគមន៍ និងមាតាបិតាសិស្ស ដើម្បីដោះស្រាយបញ្ហាប្រឈមនានានៅសាលារៀន និងធានាឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ សាលារៀនត្រូវពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិអប់រំ និងប្រើប្រាស់ប្រព័ន្ធទិន្នន័យរបស់សាលារៀនដើម្បីរៀបចំផែនការគ្រប់គ្រងគ្រូបង្រៀនតាមមុខវិជ្ជា (ដោះស្រាយបញ្ហាកង្វះគ្រូបង្រៀន) ផ្តល់សម្ភារបង្រៀន និងវិធីសាស្ត្របង្រៀន។

○ **រៀបចំផែនការអភិវឌ្ឍសាលារៀន៖** សាលារៀនត្រូវកំណត់ចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ។ សាលារៀនត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ ព្រមទាំងផែនការអភិវឌ្ឍន៍សាលារៀន ( ៦ឆ្នាំ ៣ឆ្នាំ និង ១ឆ្នាំ) រួមទាំងកម្មវិធីថ្នាក់បំប៉នសម្រាប់សិស្សរៀនយឺត ដោយមានការគាំទ្រពីសហគមន៍។

○ **អនុវត្តការធ្វើតេស្តស្តង់ដារ៖** លទ្ធផលតេស្តស្តង់ដាដែលទទួលបានពីការធ្វើតេស្តដើមឆ្នាំ ការប្រឡងប្រចាំខែ ការធ្វើតេស្តប្រចាំត្រីមាស និងតេស្តចុងឆ្នាំ ត្រូវបានប្រើប្រាស់ដើម្បីកែលម្អការបង្រៀននិងការរៀន ជាពិសេសដើម្បីជួយសិស្សរៀនយឺតដោយត្រូវកែលម្អវិធីសាស្ត្របង្រៀន ការអប់រំវិន័យវិជ្ជមាន និងការប្រឹក្សាគរុកោសល្យ។

○ **អនុវត្តវាយតម្លៃលើការបំពេញការងាររបស់មន្ត្រី៖** គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងបំពេញការងារប្រចាំឆ្នាំជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីធានាគណនេយ្យភាពជាមួយសហគមន៍។

- ដោះស្រាយបញ្ហាលើសនិងខ្វះគ្រូបង្រៀន ដោយផ្តល់ប្រាក់លើកទឹកចិត្តបន្ថែមដល់សាលារៀននៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ព្រមទាំងបន្តសាងសង់ផ្ទះគ្រូបង្រៀន និងផ្តល់ប្រាក់ឧបត្ថម្ភសមរម្យ។
- បង្កើនការចូលរួមរបស់សហគមន៍ក្នុងការបញ្ជូនកូនចៅទៅសាលារៀន និងរក្សាសិស្សឱ្យនៅបន្តរៀននៅសាលារៀន តាមរយៈការលើកទឹកចិត្តសហគមន៍ និងការចូលរួមរបស់មាតាបិតាសិស្សក្នុងការបញ្ជូនកូនគ្រប់អាយុចូលរៀនទៅសាលារៀន ជាពិសេសនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ លើកទឹកចិត្តសហគមន៍ និងមាតាបិតាសិស្សក្នុងការគាំទ្រការសិក្សារបស់សិស្ស ជាពិសេសសិស្សមានពិការភាព ដើម្បីការពារកុំឱ្យបោះបង់ការសិក្សា និងកាត់បន្ថយការរៀនត្រួតថ្នាក់។
- ពង្រឹងការធ្វើអធិការកិច្ចសាលារៀនជាប្រចាំ និងប្រើប្រាស់លទ្ធផលរបាយការណ៍អធិការកិច្ច ដើម្បីដោះស្រាយបញ្ហាដែលបានរកឃើញប្រកបដោយប្រសិទ្ធភាព។
- គាំទ្រសាលារៀនដោយការពង្រឹងការគ្រប់គ្រងតាមសាលារៀន ដើម្បីឈានសម្រេចបានស្តង់ដាសាលារៀនគំរូ សម្រាប់កែលម្អលទ្ធផលសិក្សារបស់សិស្ស ផ្លាស់ប្តូរទម្លាប់អនុវត្តនៅតាមសាលារៀន ពង្រឹងវិន័យ សីលធម៌ ក្រមសីលធម៌ គុណធម៌ តម្លៃ និងអាកប្បកិរិយាវិជ្ជមានរបស់

អ្នកផ្តល់សេវាអប់រំនិងសិស្សានុសិស្ស ពង្រឹងវាយតម្លៃការសិក្សារបស់សិស្ស និងអនុវត្តការធ្វើតេស្តស្តង់ដាចាប់ពីកម្រិតបឋមសិក្សាដល់មធ្យមសិក្សា ព្រមទាំងកាត់បន្ថយគម្លាតរវាងសាលារៀននៅទីប្រជុំជន និងសាលារៀននៅជនបទ។

### 5.2.4. កែលម្អកម្មវិធីសិក្សា និងម៉ោងបង្រៀន

- បង្កើត និងអនុវត្តកម្មវិធីសិក្សាបង្រៀនពេញមួយថ្ងៃ
- បង្កើនម៉ោងសិក្សាលើមុខវិជ្ជាសំខាន់ៗ ជាពិសេសមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រក្នុងកម្មវិធីសិក្សា និងបង្កើនម៉ោងស្វ័យសិក្សាតាមរយៈការបង្កើតក្លឹបសិក្សា និងប្រើប្រាស់ថ្នាលបឋម Primary Learning Platform (PLP)
- ធានាគុណភាពម៉ោងសិក្សា (ដោយមិនឱ្យមានការបាត់បង់ម៉ោងរៀនសូត្ររបស់សិស្ស ហើយសិស្សទទួលបានការសិក្សាពេញតាមម៉ោងជាក់ស្តែង) ដោយពង្រឹងវិន័យសាលារៀន ការគ្រប់គ្រងថ្នាក់រៀន និងការគ្រប់គ្រងនៅតាមសាលារៀន ព្រមទាំងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដើម្បីជាជំនួយដល់ការតាមដាន និងពង្រឹងការអនុវត្តប្រចាំថ្ងៃ
- ពិនិត្យឡើងវិញសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់ឱ្យឆ្លើយតបនឹងសំណួរតេស្តនៅក្នុង SEA-PLM
- បញ្ចូលសកម្មភាពសិក្សានិងសំណួរតេស្តផ្អែកលើបញ្ញត្តិ និងផ្តោតលើការអភិវឌ្ឍសមត្ថភាពរបស់សិស្ស និងបន្សីរវាងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន វិធីសាស្ត្របង្រៀន និងវាយតម្លៃកម្រិតថ្នាក់រៀន
- រៀបចំថ្នាក់រៀនឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសាលារៀន ដោយមានកម្មវិធីគ្រប់គ្រងការសិក្សា (LMS) និងកម្មវិធីជំនួយដល់ការរៀន (Apps)។

### 5.2.5. ពង្រឹងសមត្ថភាពគ្រូបង្រៀន និងការអនុវត្តការបង្រៀន

- ទាក់ទាញបេក្ខជនប្រឡងចូលធ្វើគ្រូបង្រៀនដែលមានសមត្ថភាព
- បញ្ចូលកញ្ចប់សិក្សាថ្នាក់ដំបូងទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន
- ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) បន្ថែមទៀតលើប្រធានបទអំណាន និងគណិតវិទ្យាថ្នាក់ដំបូង វិធីសាស្ត្របង្រៀនថ្មីៗ ការគ្រប់គ្រងថ្នាក់រៀន ជាពិសេសបច្ចេកវិទ្យា ICT ការអប់រំបរិយាបន្នវិធីសាស្ត្របង្រៀនបែបចម្រុះ ការសិក្សាសង្គម និងវាយតម្លៃការសិក្សារបស់សិស្ស
- បន្តអនុវត្តការជ្រើសរើសគ្រូបង្រៀនផ្អែកលើកិច្ចព្រមព្រៀងការងារ ដើម្បីដោះស្រាយបញ្ហាកង្វះគ្រូបង្រៀន គុណភាពគ្រូបង្រៀន និងការពង្រាយគ្រូបង្រៀន
- កែលម្អវិធីសាស្ត្របង្រៀនដោយប្រើវិធីសាស្ត្របង្រៀនថ្មីៗ ដែលប្តូរពីការឱ្យសិស្សរៀនតាមបែបទន្ទេញចាំមាត់ ទៅជារៀនឱ្យយល់ពីបញ្ញត្តិ និងការអនុវត្តក្នុងជីវភាពជាក់ស្តែង ដូចជាការគិតស៊ីជម្រៅ

ការសិក្សាតាមបែបរិះរក ការដោះស្រាយបញ្ហា និងការបង្រៀនទាក់ទងនឹងការដោះស្រាយបញ្ហាក្នុងជីវភាពជាក់ស្តែង

- លើកទឹកចិត្តគ្រូបង្រៀនឱ្យប្រើធនធានបច្ចេកវិទ្យាឌីជីថល។

### 5.2.6. កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងបរិក្ខារសាលារៀន

- សាងសង់បន្ទប់រៀនបន្ថែមដើម្បីកាត់បន្ថយផលធៀបសិស្ស-ថ្នាក់រៀន និងដោះស្រាយចំនួនសិស្សលើសច្រើនក្នុងថ្នាក់រៀន
- សាងសង់សាលាមត្តេយ្យក្នុងសាលាបឋមសិក្សាបន្ថែម ដើម្បីពង្រឹងការត្រៀមខ្លួនរបស់កុមារចូលរៀនកម្រិតបឋមសិក្សា
- បំពាក់សម្ភារបង្រៀន និងរៀន ICT ដល់សាលារៀនដើម្បីលើកកម្ពស់ការអប់រំបច្ចេកវិទ្យាឌីជីថល
- សាងសង់បណ្ណាល័យ និងប្រែក្លាយទៅជាបណ្ណាល័យអេឡិចត្រូនិក។

### 5.2.7. លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភនៅតាមសាលារៀន

- អនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ផ្តល់អាហារូបករណ៍ លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភដល់សិស្សនៅបឋមសិក្សា
- កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាព ដូចជាការរៀបចំបន្ទប់សុខភាពដែលមានស្តង់ដា និងលើកកម្ពស់បរិស្ថានសាលារៀនបៃតង និងស្អាតគ្មានសំរាមជាប្រចាំ
- លើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងការថែរក្សាអនាម័យ ដោយផ្តោតសំខាន់លើការផឹកទឹកស្អាត ការលាងដៃ ការប្រើប្រាស់បង្គន់អនាម័យត្រឹមត្រូវ ការពាក់ម៉ាស់ និងការរក្សាគម្លាត
- លើកកម្ពស់អាហារូបត្ថម្ភដោយផ្តោតលើសុវត្ថិភាពចំណីអាហារ និងការផ្តល់អាហារនៅសាលារៀន
- បញ្ចូលការអប់រំសុខភាពក្នុងកម្មវិធីសិក្សា។

# ឯកសារយោង

MoEYS. (2021). *Education in Cambodia: Results from Participation in the SEA-PLM*. Phnom Penh: Author. https://www.seaplm.org/images/DOWNLOADS/SEA-PLM_National_Report_Cambodia.pdf

UNESCO. (2018). *Global Education Monitoring Report 2019: Migration, Displacement and Education Building Bridges*, not Walls. Paris: UNESCO. https://unesdoc.unesco.org/ark:/48223/pf0000265866

UNICEF & SEAMEO. (2017). *SEA-PLM 2019 Global Citizenship Assessment Framework (1st ed.)*. Bangkok, Thailand: United Nations Children’s Fund (UNICEF) & Southeast Asian Ministers of Education Organization (SEAMEO) – SEA-PLM Secretariat. https://www.seaplm.org/PUBLICATIONS/frameworks/sea-plm%202019%20global%20citizenship%20assessment%20framework.pdf

UNICEF & SEAMEO. (2020). *SEA-PLM 2019 Main Regional Report: Children’s learning in 6 Southeast Asian countries*. Bangkok, Thailand: United Nations Children’s Fund (UNICEF) & Southeast Asian Ministers of Education Organization (SEAMEO) – SEA-PLM Secretariat. https://www.seaplm.org/PUBLICATIONS/regional%20results/SEA-PLM%202019%20Main%20Regional%20Report.pdf

UNICEF & SEAMEO. (2024). *SEA-PLM 2024 Test and questionnaire assessment framework*. Bangkok, Thailand: United Nations Children9s Fund (UNICEF) & Southeast Asian Ministers of Education Organization (SEAMEO) – SEA-PLM Secretariat. https://www.seaplm.org/images/DOWNLOADS/SEA-PLM_2024_Test_Questionnaire_Framework_Final_.pdf

UNICEF & SEAMEO. (2024). *SEA-PLM 2024 Main Regional Report, Children's learning in 6 Southeast Asian countrie*s. Bangkok, Thailand: United Nations Children's Fund (UNICEF & Southeast Asian Ministers of Education Organization (SEAMEO) – SEA-PLM Secretariat. https://www.seaplm.org/images/PUBLICATION/2025/SEA-PLM_2024_Main_Regional_Report.pdf

# ឧបសម្ព័ន្ធ១ លទ្ធផលវិភាគលម្អិតរបស់ជំពូកទី២

## 1.1. លទ្ធផលអំណានជាពិន្ទុ របស់ប្រទេសចូលរួមក្នុង SEA-PLM ឆ្នាំ២០១៩ និង២០២៤

| វដ្ត | ឡាវ | ហ្វីលីពីន | កម្ពុជា | មធ្យមអាស៊ាន | មីយ៉ាន់ម៉ា * | ម៉ាឡេស៊ី | វៀតណាម |
|---|---|---|---|---|---|---|---|
| 2019 | 275 (0.8) | 288 (0.9) | 290 (0.8) | 300 | 292 (0.8) | 319 (1.1) | 336 (0.9) |
| 2024 | 276 (0.8) | 290 (1.0) | 296 (0.7) | 300 | 305 (0.7) | 314 (1.1) | 323 (0.6) |

*លទ្ធផលរបស់មីយ៉ាន់ម៉ា មិនតំណាងឱ្យសិស្សទូទាំងប្រទេស ដោយសារស្ថានភាពផ្ទៃក្នុងប្រទេស។
លេខនៅក្នុងវង់ក្រចកជាលម្អៀងស្តង់ដា។

## 1.2. លទ្ធផលអំណានជាភាគរយសិស្សតាមកម្រិតសមត្ថភាពរបស់ប្រទេសចូលរួមក្នុង SEA-PLM ឆ្នាំ២០១៩ និង២០២៤

| អំណាន | SEA-PLM 2019 | SEA-PLM 2024 |
|---|---|---|
| កម្រិត២ និងទាបជាងនេះ | 23.7% | 16.9% |
| កម្រិត៣ | 23.7% | 19.9% |
| កម្រិត៤ | 25.1% | 24.4% |
| កម្រិត៥ | 16.5% | 20.5% |
| កម្រិត៦ និងខ្ពស់ជាងនេះ | 11.0% | 18.4% |

លទ្ធផលត្រូវបានបង្គត់ទៅខ្ទង់ទសភាគដែលនៅជិតបំផុត ដូច្នេះតម្លៃសរុបខ្លះអាចធំជាង ឬតូចជាង 100%។

## 1.3. លទ្ធផលគណិតវិទ្យាជាពិន្ទុរបស់ប្រទេសចូលរួមក្នុង SEA-PLM ឆ្នាំ២០១៩ និង២០២៤

| វដ្ត | ឡាវ | ហ្វីលីពីន | មធ្យមអាស៊ាន | កម្ពុជា | មីយ៉ាន់ម៉ា * | ម៉ាឡេស៊ី | វៀតណាម |
|---|---|---|---|---|---|---|---|
| 2019 | 279 (0.8) | 288 (0.8) | 300 | 289 (0.8) | 288 (0.6) | 315 (1.1) | 341 (1.0) |
| 2024 | 283 (0.9) | 293 (0.9) | 300 | 301 (0.8) | 307 (0.8) | 310 (1.2) | 335 (0.9) |

*លទ្ធផលរបស់មីយ៉ាន់ម៉ា មិនតំណាងឱ្យសិស្សទូទាំងប្រទេស ដោយសារស្ថានភាពផ្ទៃក្នុងប្រទេស។
លេខនៅក្នុងវង់ក្រចកជាលម្អៀងស្តង់ដា។

## 1.4. លទ្ធផលគណិតវិទ្យាជាភាគរយសិស្សតាមកម្រិតសមត្ថភាពរបស់ប្រទេសចូលរួមក្នុង SEA-PLM ឆ្នាំ២០១៩ និង២០២៤

| គណិតវិទ្យា | SEA-PLM 2019 | SEA-PLM 2024 |
|---|---|---|
| កម្រិត២ និងទាបជាងនេះ | 16.1% | 7.9% |
| កម្រិត៣ | 19.7% | 11.7% |
| កម្រិត៤ | 25.0% | 18.4% |
| កម្រិត៥ | 20.6% | 22.3% |
| កម្រិត៦ | 12.3% | 20.3% |
| កម្រិត៧ | 4.7% | 12.7% |
| កម្រិត៨ | 1.3% | 5.2% |
| កម្រិត៩ និងខ្ពស់ជាងនេះ | 0.3% | 1.6% |

លទ្ធផលត្រូវបានបង្គត់ទៅខ្ទង់ទសភាគដែលនៅជិតបំផុត ដូច្នេះតម្លៃសរុបខ្លះអាចធំជាង ឬតូចជាង 100%។

## 1.5. លទ្ធផលអំណាន និងគណិតវិទ្យាតាមភេទសិស្ស

| វគ្គ | មុខវិជ្ជា | សិស្សស្រី | សិស្សប្រុស | គម្លាតពិន្ទុ (សិស្សស្រី-សិស្សប្រុស) |
|---|---|---|---|---|
| 2019 | អំណាន | 293 (0.9) | 287 (0.9) | **7** (0.3) |
| | គណិតវិទ្យា | 291 (0.9) | 288 (0.8) | **3** (0.4) |
| 2024 | អំណាន | 301 (0.7) | 292 (1.0) | **9** (1.0) |
| | គណិតវិទ្យា | 303 (0.7) | 300 (1.1) | **3** (1.0) |

អក្សរដិតបង្ហាញពីភាពខុសគ្នាប្រកបដោយភាពជឿជាក់បាន ($p<0.05$)។
លេខនៅក្នុងវង់ក្រចកជាលម្អៀងស្តង់ដា។

## 1.6. លទ្ធផលអំណាន និងគណិតវិទ្យាតាមប្រភេទការគ្រប់គ្រងសាលារៀន

| វគ្គ | មុខវិជ្ជា | សាលាសាធារណៈ | សាលាឯកជន | គម្លាតពិន្ទុ (សាលាឯកជន - សាលាសាធារណៈ) |
|---|---|---|---|---|
| 2019 | អំណាន | 288 (0.7) | 313 (2.1) | **25** (2.2) |
| | គណិតវិទ្យា | 287 (0.7) | 314 (2.3) | **27** (2.4) |
| 2024 | អំណាន | 295 (0.7) | 313 (1.5) | **18** (1.7) |
| | គណិតវិទ្យា | 300 (0.8) | 321 (1.7) | **21** (1.9) |

អក្សរដិតបង្ហាញពីភាពខុសគ្នាប្រកបដោយភាពជឿជាក់បាន ($p<0.05$)។
លេខនៅក្នុងវង់ក្រចកជាលម្អៀងស្តង់ដា។

## 1.7. លទ្ធផលអំណាន និងគណិតវិទ្យាតាមប្រភេទទីតាំងសាលារៀន

| វគ្គ | មុខវិជ្ជា | ប្រជុំជន | ជនបទ | គម្លាតពិន្ទុ (ប្រជុំជន - ជនបទ) |
|---|---|---|---|---|
| 2019 | អំណាន | 302 (1.9) | 287 (0.8) | **15** (2.0) |
| | គណិតវិទ្យា | 301 (2.1) | 286 (0.7) | **15** (2.2) |
| 2024 | អំណាន | 304 (1.5) | 294 (0.8) | **10** (1.7) |
| | គណិតវិទ្យា | 310 (1.7) | 299 (0.9) | **11** (1.9) |

អក្សរដិតបង្ហាញពីភាពខុសគ្នាប្រកបដោយភាពជឿជាក់បាន ($p<0.05$)។
លេខនៅក្នុងវង់ក្រចកជាលម្អៀងស្តង់ដា។

## 1.8. លទ្ធផលអំណាន និងគណិតវិទ្យាតាមប្រភេទទីតាំងភូមិសាស្ត្រ

| វគ្គ | មុខវិជ្ជា | ទំនាប | បឹងទន្លេសាប | ខ្ពង់រាប | មាត់សមុទ្រ | ភ្នំពេញ |
|---|---|---|---|---|---|---|
| 2019 | អំណាន | 288 (1.2) | 292 (1.6) | 286 (1.8) | 284 (2.0) | 304 (3.4) |
| | គណិតវិទ្យា | 287 (1.1) | 291 (1.7) | 285 (1.6) | 286 (2.4) | 304 (3.7) |
| 2024 | អំណាន | 295 (1.2) | 296 (1.4) | 295 (1.6) | 299 (2.4) | 303 (1.6) |
